សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ

Université Royal de Droit et des Sciences Economiques

Royal University of Law and Economic


# សារណាបញ្ចប់ឆ្នាំសិក្សា

# ការងើបឡើងវិញនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្រោយជំងឺកូវីដ-១៩ ថមថយ

ស្រាវជ្រាវពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២ ដល់ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ និស្សិតឈ្មោះ

ឆួយ ស៊ីថេត

សាស្ត្រាចារ្យណែនាំ

បណ្ឌិត ម៉ាន់ ស៊ុនដេត


ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច

ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី ៦

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឆូយ ស៊ីថេត** ជានិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ចជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី ៦ ក្រុម D4C1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណចំពោះ

លោកឪពុក **សៅ យ៉ន** និងអ្នកម្ដាយ **អេន សើរ** អ្នកទាំងទ្វេរបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់កូន តាំងពីតូចរហូតដល់ធំពេញវ័យប្រកបដោយព្រហ្មវិហារធម៌ទាំងបួន។ គុណទាំងពីរដែលលោកអ្នកមានគុណ ទាំងពីបានផ្ដល់ឲ្យនេះ វាមានតម្លៃធំធេងខ្លាំងណាស់សម្រាប់កូន គ្មានអ្វីមកប្រៀបផ្ទឹមបានទេ ហើយក៏គ្មានថ្ងៃសងគុណអ្នកទាំងពីរួចដែរ។ អ្វីដែលកូនកំពុងធ្វើសព្វថ្ងៃដូចជា៖ ការខិតខំរៀនសូត្រ ដើម្បីទទួលបានជោគជ័យលើការសិក្សា ការខិតខំធ្វើការ ដើម្បីភាពជោគជ័យក្នុងការងារ ការខិតខំប្រតិបត្តិជាកូនល្អ ជាចៅល្អ សម្រាប់គ្រួសារ និងសង្គមជាតិ។

**ក្រសួងអប់រំ យុវជន និងកីឡា** ដែលបានផ្ដល់ឱកាសអាហារូករណ៍ដល់សិស្សដែលចប់ថ្នាក់ទី ១២ ដែលបានបញ្ចប់ថ្នាក់វិទ្យាល័យជាច្រើននាក់ក្នុងនោះក៏មានខ្ញុំបាទម្នាក់ដែរសម្រាប់ឆ្នាំសិក្សា២០១៧-២០១៨ ។

ឯកឧត្តម **សាកលវិទ្យាធិការ សាកលវិទ្យាធិការរង** ព្រមទាំងសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជាកន្លែងអប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់និស្សិតជាច្រើន មកពីគ្រប់ទិសទី។ អរគុណចំពោះការខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្រៀន ការលើកទឹកចិត្ត ការផ្ដល់នូវអនុសាសន៍ល្អ និងការចង្អុលបង្ហាញអំពីគំនិតប្រាជ្ញាផ្សេងៗ របស់សាស្ត្រាចារ្យតាមមុខវិជ្ជាទាំងដែលខ្ញុំបាទបានរៀនជាមួយ ដែលវាជាទន់ដ៏សំខាន់មួយក្នុងដំណើរជីវិតដ៏វែងឆ្ងាយរបស់មនុស្សយើងគ្រប់រូប។

លោកសាស្ត្រាចារ្យ **បណ្ឌិត ខ៉ាន់ ស៊ុនដេត** ដែលបានណែនាំបង្ហាញពីវិធីសាស្ត្រផ្សេងៗទាំងការប្រមូលទិន្នន័យ ទាំងរបៀបនៃការសរសេរ និងបានធ្វើការកែតម្រូវនូវចំនុចខ្វះខាតដែលមាននៅក្នុងសារណាខ្ញុំបាទដើម្បីទទួលបានភាពជោគជ័យលើកិច្ចការស្រាវជ្រាវនេះ។

លោក **កេត ម៉ៅ** ជាអភិបាលនៃគណៈអភិបាលស្រុកសំរោង ខេត្តតាកែវ ដែលបានអនុញ្ញាតឲ្យខ្ញុំបាទបានចុះស្រាវជ្រាវឯកសារនៅរដ្ឋបាលស្រុកសំរោង ខេត្តតាកែវ ពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២២ ដល់ថ្ងៃទី ២៧

ខែឧសភា ឆ្នាំ២០២២។ ហើយក៏សូមអរគុណទៅដល់ម្ចាស់មីក្រូសហគ្រាស និងម្ចាស់អាជីវកម្មក្រៅប្រព័ន្ធមួយចំនួនធំក្នុងស្រុកសំរោង ខេត្តតាកែវ បានផ្តល់ការសម្ភាស ឬព័ត៌មានផ្សេងៗមកដល់ខ្ញុំបាទ។

ជាទីបញ្ចប់ខ្ញុំបាទ សូមគោរពជូនពរដល់ ឯកឧត្តម សាស្ត្រាចារ្យ មិត្តរួមថ្នាក់ និងរួមជំនាន់ទាំងអស់គ្នាជួបតែសំណាងល្អក្នុងជីវិត និងមានសុខភាពមាំមួន ដើម្បីចូលរួមលើកស្ទួយវិស័យអប់រំសម្រាប់ធនធានមនុស្សជំនាន់ថ្មីក្នុងការរួមចំណែកអភិវឌ្ឍន៍សង្គមជាតិយើងទាំងមូល។

# អារម្ភកថា

គិតរាប់ចាប់ពីឆ្នាំ១៩៩៨ មក សេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជាមានភាពរីកចម្រើន និងរុងរឿងគួរឲ្យកត់សម្គាល់។ ចូលមកដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ កម្ពុជាបានចូលជាសមាជិកទី១០ របស់អាស៊ាន (ថ្មីៗ, ២០១៧, *online*)។ កម្ពុជាមានការទទួលស្គាល់ពីប្រទេសមហាអំណាចធំៗ ព្រមទាំងជំនួយអន្តរជាតិ និងការផ្តល់នូវប្រព័ន្ធអនុគ្រោះពន្ធ ដើម្បីឲ្យប្រជាជនកម្ពុជាមានការងារធ្វើគ្រប់គ្រាន់។ កម្ពុជាបានអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងល្បឿនកំណើនយ៉ាងឆាប់រហ័សមួយគួរឲ្យកត់សម្គាល់មួយ គឺមានកំណើនជាមធ្យមចំនួន ៧.៧ភាគរយក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ១៩៩៨ និងឆ្នាំ២០១៩ ដែលធ្វើឱ្យប្រទេសនេះស្ថិតនៅក្នុងចំណោមប្រទេសដែលសេដ្ឋកិច្ចមានកំណើនលឿនជាងគេនៅលើពិភពលោក (TWB, 2022, *online*)។

មកដល់ចុងឆ្នាំ២០១៩ ពិភពលោកនិយាយជារួម កម្ពុជានិយាយដោយឡែក បានបាត់បង់ទំនុកចិត្តក្នុងការពង្រីកសេដ្ឋកិច្ចលើការវិនិយោគនានា ដោយសារជម្ងឺកូវីដ១៩ បានគំរាមកំហែងខ្លាំងទៅលើប្រជាជនជាសាធារណៈនៅទីក្រុងវូហាន ខេត្តហ៊ូប៉ីនៃប្រទេសចិន ហើយមានការឆ្លងរាតត្បាតទៅខេត្តផ្សេងៗ និងរាលដាលទៅបណ្តាលប្រទេសផ្សេងៗនៅដើមឆ្នាំ២០២០។ គួបញ្ជាក់ថា បើរាប់ចាប់តាំងពីឆ្នាំ២០០០ មកឆ្នាំ២០២២ នេះ សេដ្ឋកិច្ចកម្ពុជាក៏ដូចជាសេដ្ឋកិច្ចសកលលោកបានជួបនូវវិបត្តិធំៗបី គឺ វិបត្តិហិរញ្ញវត្ថុជាសកលនៅឆ្នាំ២០០៨ វិបត្តិជម្ងឺឆ្លងកូវីដ-១៩នៅចុងឆ្នាំ២០១៩ និងថ្មីៗនេះ កើតចេញពីឥទ្ធិពលនៃសង្គ្រាមរវាងប្រទេសអ៊ុយក្រែន និងប្រទេសរុស្ស៊ី នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២។ កន្លងមកនេះ យើងឃើញថាមានអ្នកជំនាញសេដ្ឋកិច្ចជាច្រើនបានធ្វើការសិក្សាស្រាវជ្រាវទៅផលវិបាកសេដ្ឋកិច្ចដែលបានជះឥទ្ធិពលមកលើវិស័យនានាក្នុងប្រទេសកម្ពុជា ប៉ុន្តែបើតាមពិនិត្យមើលទៅចំនួនដែលបានផ្សព្វផ្សាយជាសាធារណៈនោះវាហាក់ដូចជានៅមានកម្រិតតិចតួចនៅឡើយ។ ដូច្នេះសម្រាប់កិច្ចការស្រាវជ្រាវនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការចូលរួមសិក្សាស្វែងយល់ពីការផ្លាស់ប្តូរនៃសកម្មភាពសេ្ឋកិច្ច ដោយសារកត្តាជះឥទ្ធិពលនានា ដើម្បីធ្វើការចងក្រមទុកជាឯសារសម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ។ គួរបញ្ជាក់ថា មុននឹងជ្រើសរើសប្រធានបទនេះ ខ្ញុំបាទក៏ធ្លាប់ធ្វើការសិក្សាស្រាវពីផលវិបាកនៃវិបត្តិកូវីដ១៩ទៅលើស្រ្តីដែលជាសហគ្រិន ដោយបានចុះទៅសម្ភាសន៍ជាមួយក្រុមអាជីវករដែលស្រ្តីជាគ្រប់គ្រងនៅក្នុងក្រុងសៀមរាប ដោយដោយផ្តោតលើការវាយតម្លៃនៃគុណភាពយេនឌ័រនៅក្នុងសម័យកូវីដ១៩។

បន្តពីការចង់សិក្សាស្វែងយល់បន្ថែមពីផលប៉ះពាល់នៃវិបត្តិកូវីដ១៩នៅក្នុងប្រទេសកម្ពុជា នៅក្នុងកិច្ចការស្រាវជ្រាវនេះ ខ្ញុំចង់សិក្សាពីបច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា ទៅលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលជាវិស័យងាយរងគ្រោះ និងការចាប់ផ្តើមការអាជីវកម្មឡើងវិញនិងការដំណើរការក្នុងរយៈពេល៣ត្រីមាសក្នុងឆ្នាំ២០២២

នេះ។ ជាទីបញ្ចប់ខ្ញុំបាទ សង្ឃឹមថាកិច្ចការស្រាវជ្រាវនេះ នឹងអាចជួយដល់អ្នកសិក្សាស្រាវជ្រាវទូទៅអាចយកទៅប្រើប្រាស់តាមអ្វីដែលអ្នកប្រើការបាន និងសូមធ្វើការខន្តីអភ័យទោស ចំពោះកង្វះខាតដែលកើតមានដោយអចេតនាត្រង់ចំនុចណាមួយ ហើយខ្ញុំរីករាយស្វាគមន៍ចំពោះ ការរិះគន់ក្នុងន័យស្ថាបនារាល់កំហុសឆ្គងទាំងឡាយ ពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានពីគ្រប់មជ្ឈដ្ឋានទាំងអស់ និងសូមគោរពជូនពរអ្នកទាំងអស់គ្នាឲ្យមានសុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

## មាតិកា ទំព័រ


តារាងបញ្ជីអក្សរកាត់ ---------- iv

ក្រាប ---------- v

តារាង ---------- v

ប្រអប់ ---------- v


## សេចក្តីផ្តើម


១. សេចក្តីផ្តើម ---------- ១

២. លំនាំបញ្ហា ---------- ២

៣. វត្ថុបំណងនៃការសិក្សាស្រាវជ្រាវ ---------- ៤

៤. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ ---------- ៤

៥. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ ---------- ៥

៦. សារៈប្រយោជន៍នៃការសិក្សាស្រាវជ្រាវ ---------- ៦

៧. វិធីសាស្ត្រស្រាវជ្រាវ ---------- ៦

  ៧.១. វិធីសាស្ត្រស្រាវជ្រាវ ---------- ៦

  ៧.២. វិធីប្រមូលទិន្នន័យទីពីរ និងវិធីប្រមូលទិន្នន័យទីមួយ ---------- ៦

៨. រចនាសម្ព័ន្ធ ---------- ៧


## ជំពូកទី១

## រំលឹកទ្រឹស្តីពាក់ព័ន្ធ


១.១. វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ---------- ៨

  ១.១.១ និយមន័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ---------- ៨

  ១.១.២. វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា ---------- ៩

១.២. ជំងឺកូវីដ-១៩ និងការវិវត្តនៃវិបត្តិជម្ងឺឆ្លងកូវីដ-១៩ ---------- ១១

  ១.២.១. នៅពេលកម្ពុជាតេស្តរកឃើញមានអ្នកផ្ទុកវិជ្ជមានវិរុសកូវីដ-១៩ ក្នុងគ្រាដំបូង ---------- ១១

  ១.២.២. នៅពេលកម្ពុជាមានកំណើនអ្នកវិជ្ជមានតួរលេខរហូតដល់ ៣ ខ្ទង់ ---------- ១២

  ១.២.៣. ភាពប្រសើរឡើងវិញ ក្រោមយុទ្ធនាការចាក់វ៉ាក់សាំងបង្ការ ---------- ១៤

## ជំពូកទី២

## ផលប៉ះពាល់នៃជំងឺកូវីដ១៩ មកលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ និង មីក្រូសហគ្រាសជាទូទៅ


២.១. បុគ្គលិកត្រូវបានកាត់បន្ថយឬព្យួរការងារបណ្ដោះអាសន្ន ---------------------------------------------------- ១៥

២.២. ការផ្អាកបណ្ដោះអាសន្នលើអាជីវកម្មមួយចំនួន ----------------------------------------------------------- ១៦

២.៣. ចង្វាក់នៃការផ្គត់ផ្គង់ធ្លាក់ចុះ ឬត្រូវបានកាត់ផ្ដាច់ ------------------------------------------------------- ១៩

២.៤. តម្រូវការ និងចំណូលធ្លាក់ចុះ-----------------------------------------------------------------------២០


## ជំពូកទី៣

## ការងើបឡើងវិញនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ


៣.១. សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២១-២២ -------------------------------------------------------------------២២

៣.២. ទិន្នភាពទូទៅនៃដំណើរការការងារ និងមុខរបរក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្រោយការបើកប្រទេសឡើងវិញ ក្នុងអំឡុង ១ខែ ដំបូង ---------------------------------------------------------------------------២៤

៣.៣. ការងើបឡើងវិញយ៉ាងឆាប់រហ័សនៃវិស័យទេសចរណ៍ ដែលវាជាកត្តាជំរុញ ដ៏សំខាន់សម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ------------------------------------------------------------------------------------២៦

៣.៤. កំណើននៃការតម្រូវការ ---------------------------------------------------------------------------២៩

៤. **ពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវ**

៤.១. ការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការដោះស្រាយមួយផ្នែកធំចំពោះផលវិបាកសេដ្ឋកិច្ចក្នុងសម័យកូវីដ១៩-----------------------------------------------------------------------------------------------៣១

៤.២. អតិផរណា-----------------------------------------------------------------------------------------៣៤

**សេចក្ដីសន្និដ្ឋាន** -------------------------------------------------------------------------------------៣៥

**ការផ្ដល់អនុសាសន៍** ----------------------------------------------------------------------------------៣៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# តារាងបញ្ជីអក្សរកាត់

| | |
|---|---|
| ក.ប.ស. | : ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| ក.ស.ហ. | : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| គ.វ.ក.១៩ | : គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ ១៩ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស |
| ផ.ស.ស. | : ផលិតផលក្នុងស្រុកសរុប |
| DC | : Data Commons |
| TCD | : The Cambodia Daily |
| TE | : Trading Economics |
| WB | : World Bank |
| KT | : Khmer Times |
| RFI | : Radio France International |

## ក្រាប

ក្រាបលេខ ១ ៖ ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២១ ----------------------------------២២

## តារាង

តារាងលេខ ១៖ ទំហំនៃវិស័យក្រៅប្រព័ន្ធនៅក្នុងសេដ្ឋកិច្ច (%) ------------------------------------------ ៩

តារាងលេខ ២៖ ការប៉ាន់ស្មាន និងព្យាករមកសេដ្ឋកិច្ចកម្ពុជា (%) --------------------------------------១៣

## ប្រអប់

ប្រអប់លេខ ១៖ បុគ្គលិកដែលត្រូវបានព្យួរពីការងារ ---------------------------------------------------- ១៥

ប្រអប់លេខ ២៖ អាជីវករដែលត្រូវបានផ្អាកដំណើរការ ------------------------------------------------- ១៨

ប្រអប់លេខ ៣៖ អាជីវកម្មដែលពឹងផ្អែកលើការប្រារព្ធពិធីអាពាហ៍ពិពាហ៍ -------------------------------២០

ប្រអប់លេខ ៤៖ ការងើបឡើងវិញនៃប្រាក់ចំណូលរបស់អាជីវករសំណាក់ -------------------------------២៥

ប្រអប់លេខ ៥៖ អាជីវករលក់ដូរនៅមេនីយដ្ឋានភ្នំជីសូរមានភ្ញៀវឡើងវិញ -------------------------------២៨

ប្រអប់លេខ ៦៖ ការផ្គត់ផ្គង់របស់អាជីវករទាំង២១រូប មានការកើនឡើង --------------------------------២៩

ប្រអប់លេខ ៧៖ ការប្រើប្រាស់ឌីជីថលក្នុងអាជីវកម្មរបស់អ្នកគ្រូ ឃុន ស្រីនា ---------------------------៣២

# សេចក្តីផ្តើម

អ្វីដែលចាប់ផ្តើមពីជំងឺរាតត្បាតក្នុងស្រុកនៅតំបន់មួយក្នុងទីក្រុងវូហាន ខេត្តហ៊ូប៉ីនៃប្រទេសចិន បានក្លាយជាជំងឺសកលមួយធ្វើឲ្យពិភពលោកពោរពេញដោយភាពស្លន់ស្លោ និងភ័យខ្លាច។ ដោយទទួលស្គាល់ភាពធ្ងន់ធ្ងរនៃវីរុសក្លូណាថ្មីនេះ អង្គការសុខភាពពិភពលោកនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ បានប្រកាសជាផ្លូវការថាជំងឺនេះ គឺជាជំងឺរាតត្បាតសកល ដែលមានន័យថា វាមានផលប៉ះពាល់ទូទាំងពិភពលោក (ជា, ២០២០, *online*) ។ កម្ពុជា មិនគេចផុតឡើយពីការរីករាលនៃជំងឺកូវីដ១៩ និងរងផលប៉ះពាល់របស់វា។ នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០២០ ប្រទេសកម្ពុជាបានប្រកាសករណីវិជ្ជមានដំបូងទៅលើពលរដ្ឋខ្មែរអាយុ៣៨ឆ្នាំនៅខេត្តសៀមរាប ដែលបានឆ្លងវីរុស កូវីដ១៩ ពីពាណិជ្ជករជនជាតិជប៉ុនម្នាក់ (ញឹម, ២០២០, *online*)។ បានប៉ុន្មានខែក្រោយមក ភាពស្ងប់ស្ងាត់បានត្រឡប់មកវិញ ប៉ុន្តែមិនយូរប៉ុន្មានព្រឹត្តិការណ៍ទី២បានចូលមកដល់នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលរកឃើញករណីកូវីដ១៩ លើមនុស្សចំនួន៤១នាក់ ផ្ទុះឡើងនៅតាមហាងទំនិញមួយចំនួន និងផ្សារទំនើបអ៊ីអនក្នុងរាជធានីភ្នំពេញ នេះវាមានន័យថា វាការឆ្លងចូលមកដល់សហគមន៍ហើយ ប៉ុន្មានត្រូវបានក្រុមគ្រូពេទ្យ និងក្រសួងសុខាភិបាលបានទប់ស្កាត់បាន។ ចូលមកដល់ដើមឆ្នាំ២០២១ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ ដែលជាព្រឹត្តិការណ៍ឆ្លងជាសហគមន៍ក្រោយម្តងរកឃើញអ្នកឆ្លងកូវីដ១៩ លើជនជាតិចិន៣២នាក់ ដែលករណីទាំងអស់រកឃើញនៅទីក្រុងភ្នំពេញ (អ៊ឹង, ២០២១, *online*)។

គួរកត់សម្គាល់ផងដែរថា វ៉ាក់សាំងកញ្ចប់ដំបូងនៃវ៉ាក់សាំង Sinopharm ដែលជាអំណោយរបស់ប្រទេសចិន បានមកដល់ប្រទេសកម្ពុជានៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០២១ ចូលរួមចំណែកក្នុងការការពារ និងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅកម្ពុជា ដោយបានចាក់ជូនសមាជិកព្រឹទ្ធសភា រដ្ឋសភា ទីស្តីការគណរដ្ឋមន្ត្រី កងកម្លាំងប្រដាប់អាវុធ បុគ្គលិក មន្ត្រីរាជការ និងអង្គរក្សថ្នាក់ដឹកនាំទាំងអស់ (ទិត្យ, ២០២១, *online*) ។ ក្រៅពីកម្ពុជាបានទទួលអំណោយវ៉ាក់សាំង កម្ពុជាក៏បានបញ្ជាវ៉ាក់សាំងជាច្រើនលានដុសពីបណ្តាលប្រទេសផ្សេងៗដែរជាពិសេសប្រទេសចិន សម្រាប់ចាក់ជូនប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ១៩ ឲ្យបានគ្រប់គ្នា ក្រោមយុទ្ធសាស្ត្រ "ផ្ការរីក" ស្រោចស្រពវ៉ាក់សាំងកូវីដ១៩ របស់រដ្ឋាភិបាល ដែលលទ្ធផលចាក់វ៉ាក់សាំងធៀបនឹងចំនួនប្រជាជនសរុប ១៦លាន នាក់ មាន ៩៤,២៦% គិតចាប់ពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ (គ.រ.ក.១៩, ២០២២, *online*)។ លទ្ធផលល្អប្រសើរនៃយុទ្ធនាការចាក់វ៉ាក់សាំងខាងលើ បានធ្វើឲ្យកម្ពុជាមានការគ្រប់គ្រងល្អក្នុងវិបត្តិមួយនេះ។

គួររំលឹកផងដែរថា នៅថ្ងៃទី១ វិច្ឆិកា ឆ្នាំ២០២១ រដ្ឋាភិបាលសម្រេចបើកប្រទេសឡើងវិញ ហើយអនុញ្ញាតឱ្យរដ្ឋ និងឯកជនអាចដំណើរការអាជីវកម្ម និងដំណើរការការងារជាធម្មតា ក្រោយពីរងការយាយីដោយជំងឺកូវីដ១៩ អស់រយៈពេលប្រមាណជិត ២ឆ្នាំ (TCD, ២០២១, *online*)។ ក្នុងឆ្នាំ ២០២១ សេដ្ឋកិច្ចកម្ពុជាត្រូវបានវាយតម្លៃថាងើបឡើងវិញ ក្នុងអត្រាកំណើន ៣,0% ដោយធៀបទៅនឹងការវាយតម្លៃកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០២០មានអត្រា -៣,១% ដោយសារការធ្លាក់ចុះនៃវិស័យសេវាកម្ម និងវិស័យឧស្សាហកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានព្យាករណ៍ថាសេដ្ឋកិច្ចកម្ពុជានឹងមានកំណើនដល់ទៅ ៥.៦% (ក.ស.ហ., ២០២២, *online*)។ ក្នុងការព្យាករណ៍កំណើនសេដ្ឋកិច្ចដែលមានតួលេខខ្ពស់បែបនេះ ប្រាកដណាស់វាកើតឡើងដោយសារតែវិស័យផ្សេងៗបានដំណើរការល្អប្រសើរឡើងវិញ មានដូចជា៖ ទេសចរណ៍ សំណង់ ធានាគារ រមណីយដ្ឋាន ពាណិជ្ជកម្ម អប់រំ និងវិស័យតូចធំផ្សេងៗទៀត ក្នុងនោះយើងមិនអាចមើលរំលងនូវវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធទេ ដែលវាបានដើរតួរយ៉ាងសំខាន់មួយក្នុងកំណើនសេដ្ឋកិច្ចកម្ពុជាកន្លងមក។ ដូច្នេះ ការលើកយកប្រធានបទ "**ការងើបឡើងវិញនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធក្រោយជម្ងឺកូវីដ-១៩ ថមថយ**" វាជាការចូលរួមចំណែកមួយសម្រាប់ការសិក្សាស្រាវជ្រាវ អំពីកំណើនសេដ្ឋកិច្ចក្នុងបច្ចុប្បន្នភាពរបស់កម្ពុជាដែលមាននិន្នាការងើបឡើងវិញក្រោយជួបវិបត្តិជំងឺឆ្លងកូវីដ១៩ ហើយបានចុះទៅស្រាវជ្រាវឯកសារ ពិនិត្យ អង្កេត និងជាពិសេសបានធ្វើការសម្ភាសន៍អាជីវករមួយចំនួននៅក្នុងស្រុងសំរោង ខេត្តតាកែវ។

## ២. លំនាំបញ្ហា

កម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍មួយក្នុងតំបន់នៅអាស៊ីអគ្នេយ៍ ដែលសព្វថ្ងៃនេះកម្ពុជាកំពុងអភិវឌ្ឍន៍ខ្លួន ក្នុងការចាកចេញពីប្រទេសដែលមានកម្រិតចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ យោងតាមគេហទំព័របរទេសមួយដែលមានឈ្មោះថា "Trading Economics (2022)" បានលើកឡើងថា ក្នុងឆ្នាំ២០២០ សេដ្ឋកិច្ចកម្ពុជាមានផ.ស.ស. ប្រមាណ ២៥.២៩ ពាន់លានដុល្លារអាមេរិច ដោយតម្លៃនេះវាស្មើនឹង 0.0២% នៃសេដ្ឋកិច្ចពិភពលោកទាំងមូល។ ដោយសារតែសេដ្ឋកិច្ចកម្ពុជាមានការពឹងផ្អែកខ្លាំងទៅលើសេដ្ឋកិច្ចអន្តរជាតិទាំងការនាំចេញទាំងការនាំចូល ដូច្នេះបើសិនមានការរាំងស្ទះ ឬជាប់គាំងដោយសារបញ្ហាណាមួយ នោះសេដ្ឋកិច្ចរបស់ប្រទេសនេះនឹងជួបផលវិបាកយ៉ាងឆាប់រហ័សទៅតាមកម្រិតនៃបញ្ហាទាំងនោះ តួយ៉ាងដូចជាបញ្ហានៃជម្ងឺឆ្លងកូវីដ-១៩ បានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ពាណិជកម្មអន្តរជាតិ និងជាពិសេសនោះគឺរាល់សកម្មភាពសេដ្ឋកិច្ចផ្សេងៗក្នុងស្រុកមានភាពរអាក់រអួល និងកំឡុងពេលមានការផ្ទុះខ្លាំងដែលរកឃើញអ្នកឆ្លងវីរុសនេះច្រើននាក់ ដោយមានតួលេខដ៏ទៅ ៣ ខ្ទង់ ប្រទេសនេះបានបិទ

ខ្ទប់ទីក្រុងធំៗ មានដូចជា៖ ភ្នំពេញ ព្រះសីហនុ ខេត្តក្រុងមួយចំនួននៅតាមបណ្តោយព្រំដែនថៃ និងវៀតណាម និងតំបន់ផ្សេងៗទៀត ។ ទាំងនេះជាមូលហេតុដ៏ចម្បងមួយ ដែលធ្វើឲ្យកំណើនសេដ្ឋកិច្ចរបស់កម្ពុជាបានធ្លាក់ចុះដល់ទៅ -៣.១% ក្នុងឆ្នាំ២០២០ (DC, ២០២០, *online*) ។ លោក ជា មុយគីម (២០២០) បានកត់សម្គាល់ថា ការអនុវត្តគម្លាតសុវត្ថិភាពសង្គមបែបនេះ បានធ្វើឲ្យអាជីវកម្មគ្រប់ទំហំត្រូវបានរងផលប៉ះពាល់ដោយផ្ទាល់និងដោយប្រយោលពីជម្ងឺកូវីដ១៩។ ការបិទទ្វារបណ្តោះអាសន្ននៃសាលារៀន ភោជនីយដ្ឋាន តំបន់ទេសចរណ៍ និងទីសាធារណៈផ្សេងៗទៀត ក៏មានន័យថា ការផ្អាកការងារបណ្តោះអាសន្នរបស់បុគ្គលិក កម្មករ និយោជិក ប្រតិបត្តិការអាជីវកម្ម និងសកម្មភាពទាក់ទងនឹងសេដ្ឋកិច្ចផ្សេងទៀតដូចគ្នា។

គួរបញ្ជាក់ថា នៅថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០២២ ក្រសួងសុខាភិបាលបានប្រកាសពីករណីជាសះស្បើយ អ្នកជំងឺកូវីដ ១៩ ចំនួនម្នាក់ចុងក្រោយ ដែលធ្វើឱ្យកម្ពុជាមិនមានអ្នកជំងឺកូវីដ ១៩ ទៀតឡើយ (មុំ, ២០២២, *online*)។ ហើយនៅថ្មីនេះ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ ដែលមិនទាន់បានចាក់ដូសទី៣ ទៅទទួលយកវ៉ាក់សាំងដូសទី៣ ទាំងអស់គ្នា ដើម្បីការពារកុំឱ្យឆ្លងជំងឺកូវីដ១៩ ទោះបីជាស្ថានភាពកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា មានការធូរស្បើយដោយគ្មានអ្នកឆ្លងរយៈពេលជិត២ខែមកហើយក៏ដោយ (FN, ២០២២, *online*) ។ នេះជាអ្វីដែលអាជីវករគ្រប់ចង់បានវាត្រឡប់មកនូវការដំណើររកស៊ីបានធម្មតា ដោយមានអថិជនមកទិញទំនិញ និងសេវារបស់ខ្លួន ហើយថែមទាំងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ដល់អ្នកមានតម្រូវការទាំងនោះ ដោយឈប់ភ័យព្រួយជាមួយវិបត្តិជំងឺឆ្លងកូវីដ១៩ខាងលើទៀតហើយ។ បើគិតចាប់ពីដើមឆ្នាំ២០២២ មកដល់បច្ចុប្បន្នយើងនេះ យើងឃើញថាកម្ពុជាបានស្តារសេដ្ឋកិច្ចជាតិឲ្យមានល្អប្រសើរឡើងវិញ ដោយដាក់ចេញនូវផែនការច្បាស់ដ៏មានប្រសិទ្ធិភាពពីរដ្ឋាភិបាល។

ចាប់តាំងពីបើកប្រទេសវិញមក យើងអាចធ្វើការអង្កេតបានថា អាជីវករ ឬបុគ្គលិកក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ពួកគាត់ពិតជារីករាយសាទរយ៉ាងខ្លាំងនៅពេលប្រទេសកម្ពុជារបស់យើងមានសុខសុវត្ថិភាពដែលអាចដំណើរការសកម្មភាពសេដ្ឋកិច្ចបានវិញ ក្រោយមានផលវិបាកសេដ្ឋកិច្ចដោយសារការផ្អាក ឬបិទបណ្តោះអាសន្នក្នុងសម័យកូវីដ ១៩។

## ៣. គម្មវត្ថុនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវលើប្រធានបទ "**ការងើបឡើងវិញនៃវិស័យសេដ្ឋកិច្ចកិច្ចក្រៅប្រព័ន្ធក្រោយជម្ងឺកូវីដ-១៩ ថមថយ**" រួមមានដូចខាងក្រោម៖

- ស្វែងយល់ពីឥរិយាបថរបស់ភ្នាក់ងារសេដ្ឋកិច្ចផ្សេងៗក្នុងវិបត្តិជម្ងឺឆ្លងកូវីដ ១៩
- សិក្សាពីផលប៉ះពាល់នៃជម្ងឺកូវីដ ១៩ ទៅវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងស្រុកសំរោង ខេត្តតាកែវ
- ការរៀនរស់ជាមួយជំងឺឆ្លងរបស់អ្នកភូមិមួយចំនួនក្នុងស្រុកសំរោង ខេត្តតាកែវ
- ការប្រើប្រាស់ប្រព័ន្ធឌីជីថលរបស់អាជីវករដែលមាននៅទីតាំងក្នុងស្រុកសំរោង ខេត្តតាកែវ និងស្វែងរកនូវគំហើញថ្មីៗដែលមានក្នុងដំណើរអាជីវកម្មរបស់ពួកគេ
- សិក្សាពីការងើបឡើងវិញនៃវិស័យកិច្ចក្រៅប្រព័ន្ធក្រោយជម្ងឺកូវីដ-១៩ ថមថយ នៅក្នុងស្រុកសំរោង ខេត្តតាកែវ។

## ៤. ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្នុងសម័យកាលកូវីដ ១៩ នៅក្នុងប្រទេសកម្ពុជា គឺយើងគិតចាប់ពីដើមឆ្នាំ២០២០ រហូតដល់ចុងឆ្នាំ ២០២១ បើតាមការធ្វើអង្កេតទៅអាជីវករជាទូទៅមាននៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធមានដូចជា៖ អ្នកលក់ផលិតផលជាទំនិញ(អាហារ, សម្ភារះប្រើប្រាស់, សម្លៀកបំពាក់, ...ផ្សេងៗគ្រប់ប្រភេទ) និងអ្នកលក់ផលិតជាសេវា (អ្នករត់ម៉ូតូកង់បី, ជាងកាត់សក់ ធ្វើសក់, អ្នករៀបចំកម្មពិធីផ្សេងៗ ។ល។) ដែលយើងអាចមើលឃើញថា ភាគច្រើនពួកគាត់មានអាយុលើសពី២៥ឆ្នាំ ហើយកម្រិតអប់រំរបស់ពួកគាត់គឺនៅមានកម្រិត ដោយសារតែពួកគាត់ជាធនធានដែលបន្សល់ពីសង្គ្រាមដ៏រ៉ាំរ៉ៃកាលពីអតីតកាល នោះពួកគាត់ងាយនឹងរងគ្រោះដោយសារវិបត្តិនៃជំងឺឆ្លងនេះ។ ម្យ៉ាងវិញទៀត ប្រសិនបើពួកគាត់មានផលវិបាកសេដ្ឋកិច្ចដោយសារតែជំងឺកូវីដ១៩នេះ ហើយមានកាតព្វកិច្ចសងបំណុលធនាគារ ឬឯកជនថែមទៀតនោះ ច្បាស់ណាស់ពួកគាត់ប្រាកដជាមានបញ្ហាផ្លូវចិត្តទៅតាមទំហំនៃផលប៉ះពាល់ទាំងនោះ ឬទំហំនៃចំណាយ និងចំណូល។ ហេតុនេះហើយទើបខ្ញុំបាទ សម្រេចជ្រើសរើសយកបញ្ហាទាំងនេះ មកធ្វើជាប្រធានបទស្រាវជ្រាវលើកមកបង្ហាញ ដោយធ្វើការពិពណ៌នាជុំវិញស្ថានភាពផ្សេងៗនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលកើតមាននៅក្នុងសម័សកូវីដ១៩។ ដើម្បីពិនិត្យទៅលើបញ្ហានានាដូចដែលបានរៀបរាប់ពីខាងដើម ខ្ញុំបាទសូមធ្វើការចោទជាសំណួរដូចខាងក្រោម៖

១. តើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធមានផលវិបាកសេដ្ឋកិច្ចយ៉ាងដូចម្តេចខ្លះក្នុងសម័យកូវីដ១៩?

២. ក្រោយពេលជំងឺកូវីដ ១៩ ថមថយក្នុងមួយរយៈពេលចុងក្រោយនេះ តើស្ថានភាពសេដ្ឋកិច្ចរបស់វិស័យក្រៅប្រព័ន្ធមានការងើបឡើងវិញយ៉ាងដូចម្តេច?

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

បន្ទាប់ពីតួនាទីដ៏សំខាន់របស់សហគ្រាសធុនមីក្រូ តូច និងមធ្យម វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធក៏ត្រូវបានចាត់ទុកថាជាក្បាលម៉ាស៊ីននៃកំណើននៅក្នុងបណ្តា ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍ ដោយសារការរួមចំណែករបស់វានៅក្នុងការជំរុញល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច និង បង្កើតការងារជាច្រើនដល់ប្រជាពលរដ្ឋក្នុងប្រទេស។ ដូច្នេះប្រធានបទ "**ការងើបឡើងវិញនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធក្រោយជម្ងឺកូវីដ-១៩ ថមថយ**" នេះនឹងផ្តល់ប្រយោជន៍ដល់៖

- អ្នកធ្វើផែនការ ឬអ្នកធ្វើនយោបាយម៉ាក្រូសេដ្ឋកិច្ច និងជាពិសេសអ្នកមានត្រូវការប្រមូលទិន្នន័យ ដែលទាក់នឹងការស្តារសេដ្ឋកិច្ចឡើងវិញក្រោយទទួលរងឥទ្ធិពលអវិជ្ជមាននៃវីរុសកូរ៉ូណានេះ សម្រាប់ទៅធ្វើសេចក្តីសម្រេចផ្សេងៗ។
- អ្នកដែលមានបំណងឈានជើងចូលក្នុងវិស័យនេះ ដែលចង់ធ្វើការស្វែងយល់ពីមូលហេតុនៃផលប៉ះពាល់ និងដំណោះស្រាយ ទុកជាបទពិសោធន៍មួយ ដើម្បីធ្វើជាមូលដ្ឋាននៃចំណេះដឹងក្នុងករណីដែលពួកគេអាចជួបវិបត្តិប្រភេទនេះនៅថ្ងៃអនាគត។
- អាជីវករដែលទទួលរងផលប៉ះពាល់ទាំងស្រុង ឬខ្លាំងក្នុងសម័យនោះ មានឱកាសបង្ហាញប្រាប់ពីផលវិបាកផ្សេងៗដែលពួកគេបានជួប ទៅកាន់អ្នកដែលរងផលប៉ះពាល់ដោយប្រយោល និងអាជីវករដែលមិនរងផលប៉ះពាល់សោះហើយថែមទាំងមានកំណើនប្រាក់ចំណូលទៀតផង ឲ្យបានដឹងក្នុងសម័យ។
- ជាឯកសារមួយសម្រាប់អ្នកសិក្សាផ្សេងដែលអាចយកទៅប្រើប្រាស់ទៅតាមមធ្យោបាយរបស់ពួកគេរៀងៗខ្លួន។

## ៦. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ទំហំនៃការសិក្សាស្រាវជ្រាវលើប្រធានបទនេះគឺផ្តោតលើ ការងើបឡើងវិញនៃវិស័យកិច្ចក្រៅប្រព័ន្ធ និងមីគ្រូសហគ្រាសក្រោយជម្ងឺកូវីដ-១៩ ថមថយ នៅក្នុងស្ថានភាពសេដ្ឋកិច្ចកម្ពុជាក្រោយការប្រកាសបើកប្រទេសឡើងវិញ បន្ទាប់បិទជិត២ឆ្នាំ។

ដែនកំណត់នៃការសិក្សាស្រាវជ្រាវគឺ ការងើបឡើងវិញនៃវិស័យកិច្ចក្រៅប្រព័ន្ធក្រោយជម្ងឺកូវីដ-១៩ ថមថយ ចំពោះឃុំចំនួន៣ (ឃុំស្លា, ឃុំរៀង, និងឃុំជើងគួន) នៅក្នុងស្រុកសំរោង ខេត្តតាកែវ ពីចន្លោះឆ្នាំ ២០២០ ដល់ឆ្នាំ២០២២។

## ៧. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការសរសេរ និងសិក្សាស្រាវជ្រាវលើប្រធានបទ "**ការងើបឡើងវិញនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធក្រោយជម្ងឺកូវីដ-១៩ ថមថយ**" នេះ យើងបានប្រើប្រាស់វិធីសាស្ត្រគុណវិស័យ។ ដោយឡែកចំពោះការប្រមូលទិន្នន័យវិញ យើងមានតម្រូវការទិន្នន័យពីរប្រភេទ គឺទិន្នន័យទី១ និងទិន្នន័យទី២។

### ៧.១. ទិន្នន័យទី១ ឬទិន្នន័យចម្បង

ក្នុងការប្រមូលទិន្នន័យទី១នេះ យើងបានរៀបចំជាកម្រងសំណួរដោយបានបែងចែកជា ៣ ផ្នែកធំៗ៖ ផ្នែកទី១ : ពត៌មានទូទៅរបស់ម្ចាស់អាជីវកម្ម, ផ្នែកទី២ : ស្ថានភាពសេដ្ឋកិច្ចក្នុងសម័យកូវីដ ១៩, និងផ្នែកទី ៣ : ស្ថានភាពសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ១៩មានការថមថយ ដើម្បីយកវាទៅសម្ភាសន៍ដល់ម្ចាស់អាជីវកម្ម ២១ នាក់ ដែលរងផលប៉ះពាល់នៅក្នុងចំណោមឃុំទាំងបី នៃឃុំទាំង១១ ក្នុងស្រុកសំរោង ខេត្តតាកែវ។

### ៧.២. ទិន្នន័យទី ២

ចំពោះការប្រមូលទិន្នន័យទី២នេះវិញ គឺយើងបានចុះទៅរដ្ឋបាលស្រុកសំរោង ខេត្តតាកែវដោយផ្ទាល់ ដែលបានចំណាយពេល ១ ខែ ដើម្បីពិនិត្យមើលទៅកម្រិត ឬទំហំនៃការឆ្លងរីករាលដាលនៃជម្ងឺកូវីដ១៩នេះ មកលើប្រជាពលរដ្ឋក្នុងស្រុងទាំងអស់។ ក្រៅពីនេះ យើងបានធ្វើការស្វែងរក និងប្រមូលទិន្នន័យពីប្រភពផ្សេងៗដែលបានធ្វើការចុះផ្សាយនានាមានដូចជា៖ រដ្ឋាភិបាល, អង្គការមិនមែនរដ្ឋាភិបាល, សារពត៌មានជាតិ និងអន្តជាតិ, របាយការណ៍ស្រាវជ្រាវផ្សេងៗ, គេហទំព័រនៅលើប្រព័ន្ធអ៊ីធើណេត, និងជាពិសេសកម្រងឯក

សារដែលមាននៅក្នុងបណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។

ជាការពិតណាស់ ក្រោយពីទទួលបានទិន្នន័យទាំងពីរខាងលើ យើងបានរៀបចំចងក្រមទៅតាមលំដាប់លំដោយ ដើម្បីឲ្យលោកអ្នកអានងាយយល់ ដោយធ្វើការវិភាគឲ្យបានស៊ីជម្រៅលើប្រធានបទនេះ ដែលយើងបានភ្ជាប់ជាមួយការអង្កេតផ្សេងៗដែលអ្នកផ្តល់បទសម្ភាសន៍មិនបានរៀបរាប់គ្រប់ជ្រុងជ្រោយ និងបូករួមជាមួយបទពិសោធន៍បានខ្ញុំបានជួបប្រទះផ្ទាល់ក្នុងសម័យកូវីដ១៩នេះ។

## ៨. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះរចនានៃការស្រាវជ្រាវនេះត្រូវបានចែកចេញជា ៣ ជំពូកធំៗ គឺ៖

ជំពូកទី១៖ រំលឹកទ្រឹស្តីពាក់ព័ន្ធ ដែលរៀបរាប់អំពីវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនិងវិបត្តិកូវីដ១៩នៅកម្ពុជា

ជំពូកទី២៖ ផលប៉ះពាល់នៃជំងឺកូវីដ១៩ មកលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងមីក្រូសហគ្រាសជាទូទៅ ដោយធ្វើការពណ៌នាអំពីផលវិបាកសេដ្ឋកិច្ចដែលរងទង្គិចពីជំងឺកូវីដ១៩មានដូចជា ព្យួរការងារបណ្តោះអាសន្ន, ការផ្អាកបណ្តោះអាសន្នលើអាជីវកម្មមួយចំនួន, ការធ្លាក់ចុះនៃការផ្គត់ផ្គង់សម្រាប់ចង្វាក់ផលិតកម្ម, និងចំណូលរបស់អាជីវកម្មធ្លាក់ចុះ

ជំពូកទី៣៖ ការងើបឡើងវិញនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលបរិយាយអំពីសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២១-២២, សេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្រោយសន្ទុះនៃវិស័យទេសចរណ៍ និងកំណើននៃការតម្រូវការ។

ចុងបញ្ចប់ពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវ បរិយាយអំពីការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងអាជីវកម្ម និងបញ្ហានៃកំណើនអតិផរណា។

# ជំពូកទី១

# រំលឹកទ្រឹស្តីពាក់ព័ន្ធ

## ១.១. វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

### ១.១.១ និយមន័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

សេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវបានគេកំណត់និយមន័យច្រើនប្រភេទផ្សេងៗគ្នា៖

តាមការកំណត់និយមន័យរបស់អង្គការ ILO (២០០៦, ទំព័រទី ២៨) សេដ្ឋកិច្ចក្រៅប្រព័ន្ធ៖

- ត្រូវកាន់កាប់ និងដំណើរការដោយក្រុមគ្រួសារ : សហគ្រាសនានាដែលជាក្រុមហ៊ុនសាធារណៈ និងសហគ្រាសទាំងឡាយដែលមានប្រើប្រព័ន្ធ គណនេយ្យហិរញ្ញវត្ថុ ស្រដៀងគ្នានឹងក្រុមហ៊ុនសាធារណៈមិនត្រូវបានរាប់បញ្ចូលទេ។
- មាននិយោជិកជាប់លាប់តិចតួចដែលមានប្រាក់ឈ្នួល : ភាពខុសគ្នាត្រូវបានបង្ហាញ រវាងសហគ្រាសក្នុងវិស័ុក្រៅប្រព័ន្ធដែលគ្មាននិយោជិកជាប់លាប់ដែលមានប្រាក់ឈ្នួល និងសហគ្រាសទាំងឡាយដែលមាននិយោជិកជាប់លាប់ម្នាក់ ឬច្រើននាក់ ដែលមានប្រាក់ឈ្នួល។ សហគ្រាសដំណើរការជាលក្ខណៈគ្រួសារដែលមាននិយោជិកជាប់លាប់មានប្រាក់ឈ្នួល ច្រើនជាងចំនួនកំណត់មួយ ប្រហែលជាមិនត្រូវបានរាប់បញ្ចូលទេ អាស្រ័យលើកាលៈទេសៈជាតិ។
- មិនមែនកសិកម្ម : សម្រប់ការអនុវត្តជាក់ស្តែង សហគ្រាសគ្រួសារដែលពាក់ព័ន្ធនឹងសកម្មភាពកសិកម្ម ជាទូទៅត្រូវបានដាត់ចេញពីវិស័យក្រៅប្រព័ន្ធ។ ប្រទេសខ្លះក៏មិនរាប់បញ្ចូលបុគ្គលិកបំរើការតាមផ្ទះដែលមានប្រាក់ឈ្នួល។

តាមរយៈទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា (២០០៩) ក៏បានកំណត់និយមន័យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធថា ជាសេដ្ឋកិច្ចទីផ្សារមួយចំណែកដែលមានលក្ខណៈមិនរៀបរយ មិនទាន់មានច្បាប់គ្រប់គ្រងល្អ ហើយធ្វើការផលិតទំនិញ និងសេវាសម្រាប់លក់ ឬសម្រាប់ធ្វើការទូទាន់ផ្សេងៗ។

ដោយឡែកលោក ឫទ្ធីពល (Rithipul, ២០២១) បានឲ្យនិយមន័យ «សេដ្ឋកិច្ចក្រៅប្រព័ន្ធ» ឬភាសាអង់គ្លេសហៅថា "Informal economy" មានន័យថា ប្រព័ន្ធនៃការធ្វើពាណិជ្ជកម្ម ឬ ការដោះដូរទំនិញនិង សេវា ដែលច្បាប់មិនតម្រូវឱ្យចុះបញ្ជី។ សេដ្ឋកិច្ចក្រៅប្រព័ន្ធផ្តល់នូវការបង្កើតមុខរបរការងារធ្វើនិងប្រាក់ ចំណូល ប៉ុន្តែ អាចបង្កឱ្យមានផលវិបាកក្នុងការគ្រប់គ្រងបរិស្ថានសុវត្ថិភាពចំណីអាហារ ការប្រមូលពន្ធ ជាដើម។

ដូច្នេះ ក្នុងន័យការងារ សេដ្ឋកិច្ចក្រៅប្រព័ន្ធ រួមបញ្ចូលសកម្មភាព មួយចំនួនធំដូចជាមុខរបរចញ្ចឹមជីវិត ឬមុខរបរសំរាប់តែមួយរស់ និងអ្នកដែលប្រកបការងារដោយខ្លួនឯង ព្រមទាំងអ្នកធ្វើការមានប្រាក់ឈ្នួល និងគ្មានប្រាក់ឈ្នួលនៅក្នុងសហគ្រាសក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។ អ្នកធ្វើការខ្លះនៅក្នុងសហគ្រាសក្នុងប្រព័ន្ធ ត្រូវបានគេរាប់បញ្ចូលជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រោះនិយោជករបស់ពួកគេមិនបានប្រកាសជូនដំណឹងអំពីបុគ្គលិកដល់ក្រសួងការងារ។ ទាក់ទងនឹងផលិតភាព និងទំហំ សេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជាគ្របដណ្តប់លើសហគ្រាសមួយធំ រួមបញ្ចូលទាំងសហគ្រាសធុនតូច និងមធ្យមដែលយកផ្ទះរបស់ខ្លួនធ្វើជាមូលដ្ឋាន (ILO, 2006, p.15)។

នៅទីក្រុងភ្នំពេញ មុខរបរក្រៅប្រព័ន្ធរួមមាន ៖ អ្នកលក់តាមដងផ្លូវ អ្នករត់ម៉ូតូឌុប អ្នករត់កង់បី អ្នករត់តាក់ស៊ី អ្នកស៊ីក្លូ អ្នករើសអេតចាយ អ្នកជួសជុសយានយន្តតាមចិញ្ចើមថ្នល់ អ្នកលក់ចាំងតាមចិញ្ចើមថ្នល់ ជាងកំបោរ កម្មករសំណង់ សិល្បករ ជាងកាត់ដេរសំលៀកបំពាក់ អ្នកបម្រើតាមផ្ទះ និងមុខរបរ ឬការងារផ្សេងៗទៀត។

## ១.១.២. វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា

បើយើងក្រឡេកទៅមើលស្ថានភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធមុនឆ្នាំ២០០៣ មកដោយោយងតាមការសិក្សាស្រាវជ្រាវរបស់ ILO (២០០៦) គឺសេដ្ឋកិច្ចក្រៅមានការរីកចម្រើនខ្លាំងដោយបានបង្កើតការងារជាច្រើនដល់ប្រជាពលរដ្ឋកម្ពុជា និងមានទំហំធំក្នុងការរួមចំណែកចំពោះផ.ស.សរបស់សេដ្ឋកិច្ចជាតិ (តារាងលេខ ១)។

តារាងលេខ ១៖ ទំហំនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងសេដ្ឋកិច្ចជាតិ (%)

| | ១៩៩៨ | ២០០០ | ២០០៣ |
|---|---|---|---|
| កំលាំងពលកម្ម | ៨៥% | ៨៥% | ៨៥% |
| ផ.ស.ស | ៧០% | ៦៤% | ៦២% |

ប្រភព ៖ ILO, ២០០៦, ការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា, ទំព័រ ១៧

ដោយយោងតាមអត្ថបទរបស់ MLVT (២០១៩) ដែលរៀបរាប់ពីការចុះផ្សាយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានលើកឡើងថា ៖ គោលនយោបាយជាតិស្តីពី មុខរបរ និងការងារ គោលដៅលើកកម្ពស់ការងារសមរម្យ និងមានផលិតភាពការងារខ្ពស់ តាមរយៈការបង្កលក្ខណៈឱ្យមានការប្រែក្លាយកម្មករនិយោជិត និងអង្គភាពពីសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅក្នុងសេដ្ឋកិច្ចផ្លូវការ ដោយធានាបាននូវការកែលម្អ និងរក្សាបាននូវជីវភាពរស់នៅក្នុងអំលុងពេលនៃដំណើរការប្រែក្លាយនេះ។ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦-២០២៥) ក៏បានគ្របដណ្តប់លើអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការដាក់ឱ្យដំណើរការរបបថែទាំសុខភាពសង្គម ដោយគោលការណ៍ស្ម័គ្រចិត្តក្នុងដំណាក់កាលដំបូង បន្ទាប់មកពិនិត្យលទ្ធភាពក្នុងការបង្វែរទៅជារបបកាតព្វកិច្ច យោងទៅតាមស្ថានភាពជាក់ស្តែង។ ច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជាមិនបានរើសអើង ឬបែងចែករវាងកម្មករនិយោជិតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬក្នុងប្រព័ន្ធទេ ពោលគឺច្បាប់នេះមានវិសាលភាពគ្របដណ្តប់ចំពោះគ្រប់កម្មករនិយោជិតទាំងអស់ ដែលមានទំនាក់ទំនងការងារជាមួយនិយោជក។ មិនតែប៉ុណ្ណោះប្រភពដដែរនេះបានបន្តទៀតថា ៖ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ ២០១៧ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីប្រកាសមួយស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម សម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន ដែលមានគោលបំណងកំណត់ការអនុវត្តការថែទាំសុខភាព តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម ពេលសម្រាលកូនជូនកម្មករនិយោជិតជាស្ត្រីទាំងក្នុង និងក្រៅប្រព័ន្ធ, នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ បានចេញសេចក្តីប្រកាសមួយស្តីពីលក្ខខណ្ឌការងារសម្រាប់កម្មករការងារតាមផ្ទះ , និងនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ក៏បានប្រកាសពី លក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត។

គួរបញ្ជាក់ថា បើយោងតាមការស្រាវជ្រាវរបស់ ILO នៅឆ្នាំ២០២១ បានបង្ហាញថា៖ វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធតំណាងឱ្យ ៨៧.៥% នៃសេដ្ឋកិច្ចកម្ពុជា ហើយក្រសួងផែនការបានលើកឡើងថា កម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធចំនួន ៦ លាននាក់ កំពុងប្រឈមនឹងការបាត់បង់មុខរបររបស់ពួកគេ នៅក្នុងអំឡុងពេលដែលជំងឺកំពុងរាតត្បាតជាសកល ។

## ១.២. ជំងឺកូវីដ-១៩ និងការវិវត្តនៃវិបត្តិជម្ងឺឆ្លងកូវីដ-១៩

COVID-19 គឺជាជំងឺផ្លូវដង្ហើមដែលបង្កឡើងដោយសារវីរុសក្លូរ៉ូណា (WSDH, N/A, *online*) ។ វីរុសថ្មីនេះត្រូវបានគេរកឃើញ និងរាយការណ៍ថាជំងឺមួយដែលត្រូវបានចម្លងពីសត្វទៅមនុស្សដោយមានប្រភពមកពីផ្សារអាហារសមុទ្រនៅទីក្រុងវូហានដែលសត្វព្រៃ ដូចជាទន្សាយ ប្រចៀវ និងពស់ ត្រូវបានលក់សេរី និងខុសច្បាប់។ គេជឿថាក្រុមមនុស្សដំបូងដែលឆ្លងវីរុសនេះ គឺក្រុមអ្នកលក់នៅផ្សារអាហារសមុទ្រវូហានដែលមានការទាក់ទងផ្ទាល់ជាមួយសត្វព្រៃទាំងនោះ។ យោងតាមការសិក្សារបស់អ្នកជំនាញខាងវីរុសសាស្ត្រនៅវិទ្យាស្ថានវូហានសម្រាប់វីរុសសាស្ត្រ ៩៦ ភាគរយនៃហ្សែនរបស់វីរុសរបស់វីរុសក្លូរ៉ូណា ដែលត្រូវបានរកឃើញនៅក្នុងមនុស្ស មានភាពដូចគ្នាទៅនឹងហ្សែនវីរុសក្លូរ៉ូណាដែលមាននៅក្នុងសត្វប្រចៀវ (ជា, ២០២០, *online*) ។ ប្រភពដដែរបានបន្តទៀតថា ក្នុងអំឡុងពេល ៣ខែ ចាប់តាំងពីការផ្ទុះឡើងនៃជំងឺនេះនៅចុងឆ្នាំ ២០១៩ ប្រទេសចិនបានឈរនៅលំដាប់កំពូលនៃបញ្ជីចំនួនអ្នកឆ្លង និងចំនួនអ្នកស្លាប់លើពិភពលោក រហូតមកដល់ថ្ងៃទី២៧ ខែមីនា ដែលសហរដ្ឋអាមេរិកបានជំនួសតំណែងនេះ ទីក្រុងញូវយ៉កបានក្លាយជា ចំនុចកណ្តាលនៃជំងឺរាតត្បាត។ ប្រទេសអ៊ីតាលី ឈរនៅលំដាប់ទី២ ក្នុងបញ្ជីបន្ទាប់មក គឺប្រទេសចិន អេស្ប៉ាញ និងអាល្លឺម៉ង់ តាមលំដាប់នៃចំនួនករណីអ្នកដែលបានឆ្លងជំងឺ។ ដោយទទួលស្គាល់ភាពធ្ងន់ធ្ងរនៃវីរុសក្លូរ៉ូណាថ្មីនេះ អង្គការសុខភាពពិភពលោកនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ បានប្រកាសជាផ្លូវការថាជំងឺនេះ គឺជាជំងឺរាតត្បាតសកល ដែលមានន័យថា វាមានផលប៉ះពាល់ទូទាំងពិភពលោក ។

### ១.២.១. នៅពេលកម្ពុជាគេស្គាល់រកឃើញមានអ្នកផ្ទុកវិជ្ជមានវីរុសកូវីដ-១៩ ក្នុងគ្រាដំបូង

គួររំលឹកផងដែលថា នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ កម្ពុជាប្រកាសករណីទី១នៃវីរុសក្លូរ៉ូណាដែលរកឃើញលើជនជាតិចិនម្នាក់នៅខេត្តព្រះសីហនុ ដែលមានឈ្មោះ ចា ជិនហួរ (Jia Jianhua) ភេទ ប្រុស អាយុ ៦០ឆ្នាំ បានធ្វើដំណើរជាមួយគ្រួសារ មានសមាជិក៤នាក់ (VOA, 2020, *online*)។ ពត៌មាននេះ វាបានធ្វើឲ្យប្រជាពលរដ្ឋកម្ពុជា និងជាពិសេសអ្នកជំនួញគ្រប់មានការបារម្មណ៍យ៉ាងខ្លាំងចំពោះការធ្លាក់ចុះនៃចំណូលរបស់ពួកគេ ដោយសារកន្លងមកពួកគេបានអាន ស្តាប់ និងឃើញពីពត៌មានបរទេសស្តីពីការប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ចពីជំងឺដ៏កាចសាហាវនេះ។

### ១.២.២. នៅពេលកម្ពុជាមានកំណើនអ្នកវិជ្ជមានតួរលេខរហូតដល់ ៣ ខ្ទង់

ក្រៅតែពីការបិទសាលារៀន ផាងកុន ខារ៉ាអូខេ ភោជនីយដ្ឋាន មជ្ឈមណ្ឌលទេសចរណ៍ និងការដាក់បំរាមគោចរជាដើម តែស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩ ឆ្លងគ្រប់ទិសទីនៅក្នុងទីក្រុងភ្នំពេញ និងតាខ្មៅបានធ្វើឲ្យរដ្ឋាភិបាលបានសម្រេច បិទរាជធានីក្នុងរយៈពេលពីរអាទិត្យនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ បើមិនដូច្នេះទេ គឺវារាលដាលទាំងអស់ហើយ មិនមានខ័ណ្ឌណាមួយដែលមិនប៉ះពាល់នោះទេ (មួង, ២០២១, *online*)។ ក្នុងពេលនោះដែរ រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្មទាំងអស់ ដែលមិនមែនជាតម្រូវការប្រចាំថ្ងៃ ត្រូវហាមឃាត់ទាំងអស់ដែរ។ ប៉ុន្តែមិនហាមឃាត់ផ្សារ និងហាងលក់ទំនិញផ្គត់ផ្គង់ និងចំណីអាហារដែលជាតម្រូវការប្រចាំថ្ងៃនោះទេ គ្រាន់តែកម្រិតចំនួនមនុស្ស ដែលត្រូវចេញទៅទិញរបស់ចាំបាច់ដូចជាគ្រឿងហូបចុក ដោយមួយគ្រួសារឲ្យចេញបានតែម្នាក់ ឬ ពីរនាក់យ៉ាងច្រើន និងអាចចេញពីផ្ទះទៅទិញរបស់ទាំងនេះ បានតែ ៣ ដងក្នុងមួយសប្តាហ៍ ដោយត្រូវបង្ហាញឯកសារបញ្ជាក់ពីអាជ្ញាធរដែនដីផង។ នៅមិនទាន់ដល់ថ្ងៃនៃការបិទបញ្ចប់ការបិទខ្ទប់រយៈពេល២សប្តាហ៍ផង រដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី២៦មេសា ឆ្នាំ២០២១ បានសម្រេចបន្ថែមការបិទខ្ទប់រាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល រយៈពេល ១សប្តាហ៍ទៀត ដើម្បីឈានដល់ការទប់ស្កាត់ការផ្ទុះឆ្លងរាលដាលជំងឺកូវីដ១៩។ សេចក្តីសម្រេចនេះ ត្រូវបានរដ្ឋាភិបាល បន្ថែមដោយការបែងចែកតំបន់ដែលត្រូវបានបិទខ្ទប់ជា ៣តំបន់ រួមមាន៖ តំបន់ក្រហម តំបន់លឿងទុំ និង តំបន់លឿង។ ដោយតំបន់ក្រហម សំដៅដល់ភូមិសាស្រ្តដែលមានការឆ្លងរាលដាលធ្ងន់ធ្ងរនៃជំងឺកូវដ-១៩ ក្នុងសហគមន៍។ ហើយតំបន់លឿងទុំវិញ សំដៅដល់ភូមិសាស្រ្តដែលមានការឆ្លងរាលដាលកម្រិតមធ្យមនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍។ ហើយចុងក្រោយ តំបន់លឿង សំដៅដល់ភូមិសាស្រ្តដែលមានការឆ្លងរាលដាលកម្រិតស្រាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ (អោ, ២០២១, *online*)។

ដោយសារការអនុវត្តន៍វិធានការប្រឆាំងនឹងជំងឺឆ្លងនេះ វាបានគម្រាមកំហែងយ៉ាងខ្លាំងទៅលើសកម្មភាពសេដ្ឋកិច្ចទៅលើវិស័យផ្សេងៗនៃការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ខណៈដែលវិស័យទេសចរណ៍ ផលិតកម្មសម្រាប់ការនាំចេញ និងវិស័យសំណង់ត្រូវបានគេមើលឃើញថាជាវិស័យដែលបានរងផលប៉ះពាល់ខ្លាំងបំផុត ដែលវិស័យទាំងបីនេះបានចូលរួមចំណែកច្រើនជាង ៧០ ភាគរយនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងបង្កើតការងារប្រហែលជា ៣៩,៥ ភាគរយនៃការងារសរុបនៅក្នុងឆ្នាំ ២០១៩(WB, 2020, *online*)។ បើយោងតាមរដ្ឋមន្ត្រីក្រសួងទេសចរណ៍នៅឆ្នាំ ២០២០ ប្រទេសកម្ពុជាត្រូវបានគេប៉ាន់ប្រមាណថានឹងខាតបង់ប្រាក់ចំណូលពីវិស័យទេសចរណ៍ប្រមាណជា ៣ ពាន់លានដុល្លារ ដែលក្នុងរយៈពេល ៤ ខែដំបូង

ភ្ញៀវទេសចរណ៍បរទេសប្រមាណជា ១,៦ លាននាក់បានមកទស្សនាប្រទេសកម្ពុជាដែលជាតួលេខបង្ហាញពីការធ្លាក់ចុះ ៥២ ភាគរយបើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ អាជីវកម្មដែលទាក់ទងនឹងវិស័យទេសចរណ៍ចំនួន ២.៩៥៦ ត្រូវបានបិទទ្វារ ដែលបណ្តាលឱ្យអត្រាភាពគ្មានការងារធ្វើមានចំនួន ៤៥.៤០៥ នាក់ (KT, 2020, *online*) ខណៈពេលដែលការប៉ាន់ស្មានពីធនាគារពិភពលោក បង្ហាញថា ជាសាកលយ៉ាងហោចណាស់មានការងារចំនួន ១,៧៦ លានកន្លែងកំពុងប្រឈមនឹងការបាត់បង់ (WB, 2020, *online*)។ យោងតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រោងចក្រសរុបចំនួន ៤៣៣ និងអាជីវកម្មដែលទាក់ទងនឹងវិស័យទេសចរណ៍នៅទូទាំងប្រទេសបានបិទទ្វារជាបណ្តោះអាសន្ន (សែន, 2020, *online*)។ តាមប្រភពបានបញ្ជាក់ទៀតថា ការបិទទ្វារជាបណ្តោះអាសន្ននេះ បានធ្វើឱ្យកម្មករកាត់ដេរប្រមាណជា ១៣៥.០០០ នាក់ និងកម្មករទេសចរណ៍ ១៧.០០០ នាក់គ្មានការងារធ្វើ ។

តារាងលេខ ២៖ ការប៉ាន់ស្មាន និងព្យាករមកសេដ្ឋកិច្ចកម្ពុជា (%)

| ស្ថាប័ន | មុនពេល កូវីដ-១៩ | | ក្រោយពេល កូវីដ-១៩* | |
|---|---|---|---|---|
| | ២០២០ប៉ាន់. | ២០២១ព្យា. | ២០២០ព្យា. | ២០២១ព្យា. |
| រាជរដ្ឋាភិបាលកម្ពុជា (RGC) | ៦.៥ | ៧.០ | -១.៩ | ៣.៥ |
| ធនាគារអភិវឌ្ឍអាស៊ី (ADB) | ៦.៨ | N/A | -៤.០ | ៥.៩ |
| ធនាគារពិភពលោក (WB) | ៦.៩ | ៦.៨ | -២.០ | ៤.៣ |
| មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) | ៦.៧ | ៦.៧ | -២.៨ | ៦.៨ |

*(ប៉ាន់=ការប៉ាន់ស្មាន, ព្យា=ការព្យាករ)*

*កំណត់សម្គាល់៖ ទិន្នន័យទាំងនេះត្រូវបានប្រមូលពីប្រភពផ្លូវការ ហើយទិន្នន័យ (*) ដែលបានបង្ហាញនៅក្នុងតារាងជាទិន្នន័យថ្មីបំផុតហើយទំនងជានឹងត្រូវបានធ្វើបច្ចុប្បន្នភាពបន្ត។*

ប្រភព៖ អង្គការទិន្នន័យសម្រាប់ការអភិវឌ្ឍ (២០២០)

តារាងលេខ២ខាងលើនេះ ពីការព្យាករណ៍កំណើនសេដ្ឋកិច្ចមុនពេល និងក្រោយពេលការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ត្រូវបានគេមើលឃើញថាមានភាពខុសគ្នាទៅតាមស្ថាប័នផ្សេងៗគ្នា រួមមានការព្យាករណ៍របស់រាជរដ្ឋាភិបាលកម្ពុជាផងដែរសម្រាប់ឆ្នាំ២០២០ និង២០២១។ ការធ្លាក់ចុះនេះ ដោយសារតែផលប៉ះពាល់នៃការរីករាលដាលនៃជំងឺកូវីដ-១៩ និងមួយផ្នែកទៀតដោយសារតែការធ្លាក់ចុះសេដ្ឋកិច្ចនៃប្រទេសមានសេដ្ឋកិច្ចជឿនលឿន និងសាធារណរដ្ឋប្រជាមានិតចិន បូករួមជាមួយនឹងការធ្លាក់ចុះសមត្ថភាពនាំចេញទៅកាន់ទីផ្សារនាំចេញទៅអឺរ៉ុប (ADB, ២០២០, *online*)។

### ១.២.៣. ភាពប្រសើរឡើងវិញ ក្រោមយុទ្ធនាការចាក់វ៉ាក់សាំងបង្ការ និងបើកប្រទេសវិញ

ដោយសារកម្ពុជាបានរងឥទ្ធិពលយ៉ាងខ្លាំងពី ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១ ដែលបង្កឲ្យមានភាពរអាក់រអួលដល់ដំណើរការសង្គម-សេដ្ឋកិច្ចជាតិទាំងមូលដូចជា ការអនុវត្តវិធានការបិទខ្ទប់ក្នុងទ្រង់ទ្រាយធំ ដែលត្រូវការចំណាយខ្ពស់ និង បង្កផលប៉ះពាល់ច្រើនដល់ជីវភាពរបស់ប្រជាជន។ ការដាក់ចេញនូវ ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ គឺដើម្បីបង្កើតឲ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ ២០២១ និងគួបផ្សំជាមួយនឹងជំរុញអនុវត្តវិធានការចាំបាច់ផ្សេងទៀតជាពិសេស វិធានការ ៣-កុំ និង ៣-ការពារ គឺមានសារៈសំខាន់ដ៏ធំធេង ក្នុងគោលដៅបង្កើតឲ្យបាននូវភាពនូវស៊ាំសង្គម-សេដ្ឋកិច្ច (ក.ប.ស., ២០២១, P.12)។ អត្រាចាក់វ៉ាក់សាំងស្ទើរតែ ១០០% បានធ្វើឱ្យមានការសម្រេចចិត្តបើកថ្នាក់រៀនគ្រប់កម្រិតសម្រាប់គ្រឹះស្ថានអប់រំសាធារណៈនិងឯកជនគ្រប់កម្រិតគ្រប់ក្នុងរាជធានី ខេត្តចាប់ពីថ្ងៃទី ០១ វិច្ឆិកា ២០២១ (KT, ២០២១, online)។

# ជំពូកទី២

# ផលប៉ះពាល់នៃជំងឺកូវីដ១៩ មកលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងមីក្រូសហគ្រាសជាទូទៅ

## ២.១. បុគ្គលិកត្រូវបានកាត់បន្ថយឬព្យួរការងារបណ្តោះអាសន្ន

ដោយសារអាជីវកម្មត្រូវបានផ្អាក និងចំណូលធ្លាក់ចុះ បានធ្វើឲ្យម្ចាស់សហគ្រាសជាច្រើនបានព្យាយាមកាត់បន្ថយនិងផ្អាកបុគ្គលិក ដើម្បីកាត់បន្ថយចំណាយក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។ ហើយក៏មានម្ចាស់អាជីវកម្មមួយចំនួនបានធ្វើការកាត់ប្រាក់ខែបុគ្គលិកផងដែរ។

គួរបញ្ជាក់ថា ចំពោះការកាត់បន្ថយបុគ្គលិក ឬព្យួរការងារបុគ្គលិក អាចជួយសម្រាលបានតិចតួចទេ អ្វីដែលសំខាន់នោះ គឺការជួលទីតាំងនិងអគារសម្រាប់អាជីវកម្មនេះ គឺម្ចាស់ទីតាំងទាំងនោះមិនបានបន្ធូរបន្ថយសោះ ធ្វើឲ្យម្ចាស់សណ្ឋាគារមិនអាចទ្រាំទ្រទៀតបាន ត្រូវបង្ខំចិត្តបិទទ្វារ ( ហំ, ២០២០, *online*) ។ ប្រភពដដែរនេះ បានបន្ថែមទៀតថា ចំពោះបុគ្គលិកដែលធ្វើការនៅតាមសណ្ឋាគារដែលបានបិទ ឬផ្អាកដំណើរការទាំងនោះ គឺទទួលបានប្រាក់ឧបត្ថម្ភជាបន្តបន្ទាប់ពីរាជរដ្ឋាភិបាល លើកលែងតែសណ្ឋាគារដែលមិនមានចុះបញ្ជីនៅក្រសួងទេសចរណ៍ប៉ុណ្ណោះ៕

**ប្រអប់លេខ ១៖ បុគ្គលិកដែលត្រូវបានព្យួរពីការងារ**

ការសម្ភាសមួយចំនួន បានធ្វើឡើងជាមួយបុគ្គលិកភោជនីយដ្ឋាន ខារ៉ាអូខេ និងសណ្ឋាគារ និងរោងចក្រកាត់ដេរដែលបានវិលត្រឡប់ទៅជនបទវិញ។ បុគ្គលិកសរុបចំនួន ៩ នាក់ ដែលរស់នៅក្នុងឃុំផ្សេងគ្នាក្នុងស្រុកសំរោង ខេត្តតាកែវ ត្រូវបានស្នើសុំឲ្យផ្តល់ការសម្ភាស ដើម្បីស្វែងយល់អំពីបញ្ហានានាជាច្រើនដែលពួកគេប្រឈម។ ជាមធ្យមពួកគេមានអាយុ ២៤ ឆ្នាំ និងបានបញ្ចប់ការសិក្សាត្រឹមថ្នាក់បឋមសិក្សា។ បើទោះជាពួកគេនៅជាយុវជនក៏ដោយ ពួកគេម្នាក់ៗ ត្រូវទ្រទ្រង់មនុស្សក្នុងបន្ទុកជាមធ្យមបួននាក់។ ពួកគេទាំងអស់បានបាត់បង់ការងារសម្រាប់រយៈពេលពីមួយខែទៅបីខែ បន្ទាប់ពីបានធ្វើការនៅក្នុងវិស័យទាំងនោះរៀងៗខ្លួនអស់រយៈពេល ២,១ ឆ្នាំ ជាមធ្យម។ ប្រាក់ចំណូលប្រែប្រួលក្នុងរវាងពី ១៨០-២៨០ ដុល្លាក្នុងមួយខែ។

ង៉ែត សីហា

ង៉ែត សីហា ជាបុរសអាយុ ២៣ ឆ្នាំ នៅលីវ មកពីភូមិកញ្ចាង ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ បានធ្វើការជាសន្តិសុខនៅហាងខារ៉ាអូខេមួយកន្លែងនៅក្នុងក្រុងកំពង់សោមអស់រយៈពេល ១.៨ ឆ្នាំ ប៉ុន្តែការងាររបស់គាត់បានបញ្ចប់ខែមីនា ឆ្នាំ២០២០។ គាត់បានវិលត្រឡប់មកផ្ទះវិញដើម្បីរស់នៅជាម្តាយ ដោយសារគាត់មិនអាចរកការងារធ្វើនៅកន្លែងផ្សេងបាន។ មុនពេលមានវិបត្តិកូវីដ១៩ សីហា អាចរកប្រាក់បាន ២៥០ ដុល្លារ គាត់មិនអាចសន្សំប្រាក់បានឡើយ ដោយសារគាត់ត្រូវចំណាយអស់ ១២០ ដុល្លារ ទៅលើអាហារ ការស្នាក់នៅ និងការចំណាយផ្ទាល់ខ្លួនដទៃរបស់គាត់ ហើយគាត់បានផ្ញើប្រាក់នៅសល់ចំនួន ១៣០ ដុល្លារទៅផ្ទះ ដើម្បីសងបំណុល និងការចំណាយលើការសិក្សារបស់ប្អូនៗកាត់។ ក្នុងកំឡុងពេលមករស់នៅស្រុកកំណើត គាត់បានដាំដំណាំ ចិញ្ចឹមមាន់ និងទារ និងជាពិសេសគាត់បានធ្វើស្រែនៅរដូវប្រាំង។ ហើយក៏ឈ្លៀតធ្វើការសំណង់ជាមួយអ្នកភូមិ ដើម្បីទទួលបានលុយមកបង្គប់សម្រាប់ការបង់បំណុលធានាគារ។

ក្រោយពេលជំងឺកូវីដ១៩ថមថយ តម្រូវការសត្វលើទីផ្សារដូចជា៖ មាន់ ទារ ត្រី ហាក់បីដូចជាមានត្រូវការច្រើន ហើយទីផ្សារដ៏សំខាន់របស់សីហាគឺ ក្រុមអាជីវករលក់មាន់ដុតនៅរមនីយដ្ឋានភ្នំជីសូរ នៅជិតភូមិគាត់។ ឱកាសទាំងនេះបានជំរុញឲ្យសីហាមានគំនិតមួយក្នុងការពង្រីកទ្រុងមាន់របស់គាត់ សម្រាប់ការផ្គត់ផ្គង់ទីផ្សារក្នុងតំបន់របស់គាត់ក្នុងទំរង់ធំមួយ។ សីហា គិតថារដ្ឋាភិបាលគួរបន្តអនុវត្តយុទ្ធសាស្ត្រដ៏មានប្រសិទ្ធិក្នុងការគ្រប់គ្រងវិបត្តិនៃជំងឺកូវីដ១៩ឲ្យទទួលបានជោគជ័យ និងលើកទឹកចិត្តឲ្យប្រជាជនកម្ពុជាគ្រប់រូបទៅទទួលវ៉ាក់សាំងបង្ការជំងឺកូវីដ១៩ទាំងអស់គ្នា។

## ២.២. ការផ្អាកបណ្តោះអាសន្នលើអាជីវកម្មមួយចំនួន

ក្នុងអំឡុងពេលបិទរាជធានីភ្នំពេញ និងក្រុងតាខ្មៅក្នុងរយៈពេលពីរ ទៅ បី អាទិត្យនោះ អាជ្ញាធរតំបន់នៅក្នុងរាជធានីភ្នំពេញបានសម្រេចបន្តផ្អាកដំណើរការផ្សារជាបន្តបន្ទាប់រហូតដល់មានចំនួន ២៣ ទីតាំងជាបណ្តោះអាសន្នធ្វើឡើងរយៈពេល14ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី 21 ខែមេសា ដល់ថ្ងៃទី04 ខែឧសភា ឆ្នាំ2021 ដើម្បីបង្ការ និងទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ១៩ ដល់អាជីវករ អតិថិជន ក៏ដូចជាប្រជាពលរដ្ឋដែលចេញចូលក្នុងទីតាំងផ្សារនេះ (AMS, ២០២១, online)។ សាលារាជធានីភ្នំពេញក៏បានសម្រេចផ្អាកជាបណ្តោះអាសន្នរយៈពេល២សប្តាហ៍នូវការលក់គ្រឿងស្រវឹង និងអាជីវកម្មអាហារភេសជ្ជៈគ្រប់ប្រភេទនៅក្នុង

ហាង លើកលែងតែវេចខ្ចប់តែប៉ុណ្ណោះ។ សហព័ន្ធសហជីពកម្មករក្នុងវិស័យម្ហូបអាហារ លើកឡើងថា កន្លងមក ម្ចាស់ភោជនីយដ្ឋានឬអាជីវកម្មនិងអ្នកធ្វើការក្នុងផ្នែកនេះ បានបាត់បង់ចំណូលមួយផ្នែកធំទៅហើយ បន្ថែមដោយវិធានថ្មីនេះ ជីវភាពពួកគេនឹងកាន់តែលំបាកមួយកម្រិតទៀត។ រីឯអ្នកសេដ្ឋកិច្ចវិញ ចំណាត់ការថ្មីនេះ មិនផ្តល់ផលប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាធ្ងន់ធ្ងរនោះទេ ពោលគឺវាគ្រាន់តែជាផលប៉ះពាល់មួយផ្នែកតូចតែប៉ុណ្ណោះ (អោ, ២០២១, online) ។ ក្នុងពេលនោះ យើងក៏អាចឃើញថា នៅក្នុងតំបន់ដែលត្រូវបិទខ្ទប់មានអាជីវកម្មមួយចំនួនបានបង្ខំចិត្តបិទទ្វារ ដោយសារចូលរួមរក្សាគម្លាតសង្គម និងជាពិសេសគ្មានអតិថិជនមកទិញនិងទទួលសេវា។

បើយើងក្រឡេកមកមើលអាជីវកម្មទេសចរណ៍ជាង ៥២៧ កន្លែងបានបិទប្រតិបត្តិការក្នុងរយៈពេល ៧ ខែដំបូងនៃឆ្នាំ ២០២១ ក្នុងចំណោមក្រុមហ៊ុនសរុបចំនួន ៩.៤៦៧ និងក្រុមហ៊ុនចំនួន ៣.៣៨៩ បន្ថែមទៀត បានផ្អាកសកម្មភាពរបស់ពួកគេដោយសារតែវិបត្តិកូវីដ-១៩ នៅកម្ពុជា។ អាជីវកម្មដែលត្រូវផ្អាកមានដូចជាខារ៉ាអូខេ សណ្ឋាគារ ភោជនីយដ្ឋាន ហាងម៉ាស្សា ក្រុមហ៊ុនដឹកជញ្ជូន រង្គសាល បារ ប្រតិបត្តិករទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ (ម៉ៅ, ២០២១, *online*) ។ អាជីវកម្មផ្នែកសណ្ឋាគារ នៅក្រុងព្រះសីហនុ សៀមរាប និងរាជធានីភ្នំពេញ ត្រូវបិទទ្វារស្ទើរតែទាំងអស់ទៅហើយ និងជំរុញឲ្យម្ចាស់សណ្ឋាគារទាំងនោះ ត្រូវបង្ខំចិត្តកាត់បន្ថយបុគ្គលិក ឬព្យួរការងារបុគ្គលិក ជាបណ្តោះអាសន្ន។ សណ្ឋាគារនៅភ្នំពេញបិទស្ទើរទាំងអស់ហើយប្រហែល ៩០% ( ហំ, ២០២០, *online*) ។

យើងឃើញថាអ្វីដែលជាអន្តរាគមន៍របស់រដ្ឋាភិបាលនោះគឺ នៅថ្ងៃទី ២៦ ឧសភា ឆ្នាំ២០២១ រដ្ឋាភិបាលកម្ពុជា បានសម្រេចពន្យារការលើកលែងពន្ធ ចំពោះសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ និងក្រុមហ៊ុនអាកាសចរណ៍ និង មិនតម្រូវអោយបង់ភាគទានធនារ៉ាប់រងហានិភ័យការងារ និងថែទាំសុខភាពឡើយ។ បន្ថែមលើនេះ រដ្ឋាភិបាលក៏បានសម្រេច កាត់បន្ថយការប្រាក់និងសម្រួលដល់ការខ្ចីប្រាក់របស់សហគ្រាសធុនតូច និងមធ្យម ដើម្បីអាចទទួលបានផលប្រយោជន៍ពីថវិកាពិសេស ៥០ លានដុល្លាររបស់រដ្ឋាភិបាល តាមរយៈធនាគារអភិវឌ្ឍជនបទ និងកសិកម្ម និង ១០០លានដុល្លារទៀតពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

## ប្រអប់លេខ ២៖ អាជីវករដែលត្រូវបានផ្អាកដំណើរការ

ការសម្ភាសជាមួយម្ចាស់តូប ឬអ្នកលក់មាន់ដុតចំនួន ៥ នាក់នៅរមនីយដ្ឋានភ្នំជីសូរនៅភូមិដក់ពរ ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ។ អ្នកដែលបានផ្តល់ការសម្ភាសន៍ទាំងអស់សុទ្ធតែជាស្ត្រី នេះបានបង្ហាថាមានស្ត្រីភាគច្រើនបំផុតធ្វើការក្នុងវិស័យនេះ។ ពួកគេមានអាយុចន្លោះពី ២៨ ទៅ ៤៦ ឆ្នាំ ដែលមានប្រាក់ចំណូលមិនទៀងទៅតាមរដូវបុណ្យទាន ប៉ុន្តែតាមការរៀបរាប់បានឲ្យដឹងថាពួកគាត់អាចរកចំណូលបានក្នុងរវាង ១៥០-២២០ ដុល្លាក្នុងមួយខែ។

អេន សើរ

អេន សើរ ភេទស្រី មានអាយុ ៤៥ ឆ្នាំ មានកូនសរុប ៤ នាក់ ដែលជាអាជីករលក់មាន់ដុតនៅភ្នំជីសូរចាប់តាំងមុនឆ្នាំ២០០០ មកម្ល៉េះ។ ក្រោយពេលមានសេចក្តីប្រកាសឲ្យបិទតំបន់ទេសចរណ៍នៅទូទាំងប្រទេសពីក្រសួងទេសចរណ៍មក មុខរបររកស៊ីរបស់គាត់ត្រូវបានផ្អាកដោយទុកចោលតូបលក់អស់រយៈពេលប្រហែល ៦ ខែ។ ដោយសារគាត់មិនអាចរកចំណូលដែលធ្លាប់មានដូលកាលពីមុន និងកូនៗរបស់គាត់សុទ្ធសឹងតែជាសិស្ស និងនិស្សិតដែលមិនទាន់អាចរកចំណូលជួយគាត់បាន គាត់បានព្យាយាមកាត់បន្ថយប្រចាំថ្ងៃផ្សេងដូចជា ការដាំដុះបន្លែបង្កា សម្រាប់បរិភោគក្នុងគ្រួសារ និងសល់ចំនួនអាចទៅលក់អ្នកជិតខាង ដើម្បីទទួលបានកម្រៃខ្លះ។ គាត់ក៏មានបំណុលជាមួយធនាគារផងដែរ ដែលនេះជាស្ថានភាពនៃវិបត្តិហិរញ្ញវត្ថុដែលគាត់ត្រូវដោះស្រាយ។ ជាដំណោះស្រាយរបស់គាត់ គឺគាត់បានលក់គោ ដើម្បីបានលុយសម្រាប់បង់ធានាគារសម្រាប់រយៈ ៣ ខែ និងបានស្នើសុំបន្ថែមការខ្ចីសាច់ប្រាក់ ដើម្បីមានទុនក្នុងការរកស៊ីបន្តទៀត។

លុយដែលគាត់បានខ្ចីបន្ថែមនោះ នៅដើមឆ្នាំ២០២២ គាត់បានបើកតូបជុសជុលម៉ូតូឲ្យកូនប្រុសទី ២ ក្រោយត្រឡប់ពីរៀន និងធ្វើជាងម៉ូតូនៅទីក្រុងភ្នំពេញអស់រយៈពេល ៣ ឆ្នាំ។ ដោយសារតែកូនរបស់គាត់មានជំនាញពិតប្រាកដ គាត់ទទួលបានភ្ញៀវមកធ្វើជាច្រើនជាប្រចាំ រហូតមកដល់ពេលនេះ តូបរបស់កូនគាត់មានអីវ៉ាន់ច្រើនគួរសម។

## ២.៣. ចង្វាក់នៃការផ្គត់ផ្គង់ធ្លាក់ចុះ ឬត្រូវបានកាត់ផ្តាច់

មុននឹងពណ៌នាពីការផ្គត់ផ្គង់ធ្លាក់ចុះ យើងគួរគប្បីដឹងនូវអត្ថន័យនៃពាក្យចង្វាក់នៃការផ្គត់ផ្គង់ជាមុនសិន។ នៅក្នុងទ្រឹស្តីសេដ្ឋកិច្ច ចង្វាក់នៃការផ្គត់ផ្គង់សំដៅដល់ ប្រព័ន្ធនៃអង្គភាព កម្លាំងពលកម្ម សកម្មភាពសេដ្ឋកិច្ច ព័ត៌មាន និងប្រភពធនធាន ដែលពាក់ព័ន្ធទៅនឹងការផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ទៅឱ្យអ្នកប្រើប្រាស់។ រីឯ សកម្មភាពចង្វាក់ផលិតកម្មពាក់ព័ន្ធទៅនឹងការបំប្លែង ធនធានធម្មជាតិ វត្ថុធាតុដើម និងធាតុផ្សំផលិតផ្សេងៗ ដើម្បីផលិតឱ្យក្លាយជាផលិតសម្រេច។ ជាឧទាហរណ៍សាមញ្ញ ដើម្បីផលិតបានជា ទូរស័ព្ទ iPhone មួយគ្រឿង គេត្រូវនាំចូលវត្ថុធាតុដើមពីគ្រប់ទិសទីពាសពេញពិភពលោក ដូចជាពីកូរ៉េខាងត្បូង អាល្លឺម៉ង់ បារាំង ជប៉ុន ហើយត្រូវដំឡើងក្នុងប្រទេសចិន (ឆន, ២០២០, *online*) ។ អំឡុងកន្លះសតវត្សរ៍ចុងក្រោយ ដោយសារពាណិជ្ជកម្មអន្តរជាតិ និងរលកនៃសកលភាវូបនីយកម្ម, ចង្វាក់នៃការផ្គត់ផ្គង់សកល បានកើនឡើងក្នុងកម្រិតមួយដែលមិនធ្លាប់មាន។ ភ្លាមៗ ចង្វាក់នៃការផ្គត់ផ្គង់សកល បានបន្តធ្លាក់ចុះយ៉ាងគំហុកដោយសារវិបត្តិកូវីដ១៩។ លោក ឆន ឌីណា (២០២០) ក៏បានបញ្ជាក់ពីបញ្ហានេះ ការធ្លាក់នេះដោយសាររងឥទ្ធិពលអវិជ្ជមានពីការធ្លាក់ចុះនៃសាកលភាវូបនីយកម្មនៅលើសកម្មភាពសេដ្ឋកិច្ចពិភពលោក។ ជាមួយគ្នាដែលសកលភាវូបនីយកម្ម បានបង្កើនចំណូលប្រជាជនពិភពលោក កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍប្រទេសយ៉ាងច្រើន វាក៏បង្កឱ្យមានហានិភ័យ តួយ៉ាង វិបត្តិសេដ្ឋកិច្ច វិបត្តិហិរញ្ញវត្ថុ និងវិបត្តិជម្ងឺរាតត្បាត។

ឧទាហរណ៍, ក្រោយពេលព្រំដែនកម្ពុជា-វៀតណាម បានសម្រេចបិទមិនឲ្យមានការធ្វើដំណើរចេញចូលជាបណ្តោះអាសន្នរយៈពេលមួយខែ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដចម្លងពីវៀតណាមចូលមកកម្ពុជានៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១។ បើទោះបីជាការដោះដូរទំនិញរវាងប្រទេសទាំងពីរនៅដំណើរការធម្មតា តែត្រូវអនុវត្តវិធានការរបស់ក្រសួងសុខាភិបាល។ អ្នកសេដ្ឋកិច្ចរូបនេះមើលឃើញទៀតថា ផលប៉ះពាល់លើការផ្គត់ផ្គង់បន្លែនៅកម្ពុជាដែលបណ្តាលមកពីផ្អាកការចេញចូលព្រំដែនកម្ពុជា-វៀតណាម (អេង, ២០២១, *online*)។

## ២.៤. តម្រូវការ និងចំណូលធ្លាក់ចុះ

អាជីវកម្មទាំងក្នុងនិងក្រៅប្រព័ន្ធមានការធ្លាក់ចុះប្រាក់ចំណូលយ៉ាងគំហុក បើទោះបីជាពួកគេនៅតែបន្តបើកក៏ដោយក្តី ព្រោះមនុស្សកំពុងអនុវត្តគោលការណ៍គម្លាតសុវត្ថិភាព ឬនៅដាច់ដោយឡែកពីមនុស្សដទៃទៀតដោយការនៅផ្ទះ ជាហេតុនាំឲ្យពួកគេកាត់បន្ថយការចំណាយយ៉ាងច្រើនទៅលើសម្ភារ ឬសេវាកម្មដែលមិនចាំបាច់។ ការបាត់បង់ប្រាក់ចំណូលជាបន្តបន្ទាប់នឹងប្រែទៅជាក្ស័យធនសម្រាប់អាជីវកម្ម ដែលនឹងបណ្តាលឲ្យចំនួននៃអ្នកគ្មានការងារធ្វើកាន់តែច្រើនឡើងៗ។ ការកើនឡើងនៃចំនួនអ្នកគ្មានការងារធ្វើ នឹងបង្ខំឲ្យប្រជាជនកាត់បន្ថយការចំណាយរបស់ខ្លួន ដែលនាំឲ្យមានការធ្លាក់ចុះប្រាក់ចំណូលពន្ធសម្រាប់រដ្ឋ ខណៈពេលដែលការចំណាយលើការផ្គត់ផ្គង់ដល់អ្នកបាត់បង់ការងារធ្វើកាន់តែកើនឡើង។ ខណៈពេលដែលរដ្ឋាភិបាលបានចំណាយថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់ឧបត្ថម្ភដល់កម្មករនិយោជិកចំនួន ៤០ ដុល្លារ ដែលត្រូវបានព្យួរការងារ ហើយនិយោជក ឬម្ចាស់រោងចក្រត្រូវផ្តល់ប្រាក់ ៣០ ដុល្លារ បន្ថែមទេសរុបចំនួន ៧០ ដុល្លារក្នុងមួយខែសម្រាប់កម្មាក់ (រាជបណ្ឌិតសភាកម្ពុជា, ២០២១, p. 40)។

### ប្រអប់លេខ ៣៖ អាជីវកម្មដែលពឹងផ្អែកលើការប្រារព្ធពិធីអាពាហ៍ពិពាហ៍

អ្នកមានមុខរបរដូចជា៖ សំអានការ តម្បាញសំពត់ហូល ចុងភៅ និងមុខរបរដទៃទៀតពាក់ព័ន្ធនឹងការផ្តល់ដល់ម្ចាស់កម្មពិធីផ្សេងៗដូចជាកម្មពិធីរៀបអាពាហ៍ពិពាហ៍ជាដើម បានរាយការណ៍ថាចំណូលរបស់ពួកគេបានត្រឹមចន្លោះពី ១០% ទៅ ១៥% នៃចំណូលដែលពួកគាត់អាចរកបានកាលរាជរដ្ឋាភិបាលមិនទាន់បិទកម្មពិធីបុណ្យការកាលពីឆ្នាំទៅ។ ចំពោះចំណូលនេះ ពួកគាត់អាចបានពីការជួលសម្រាប់ការធ្វើពិធីតូចៗដូចជា ពិធីសែន ដែលជំនួសឲ្យពិធីរៀបអាពាហ៍ពិពាហ៍ និងពិធីភ្ជាប់ពាក្យជាដើម។ពួកគាត់បានបន្ទោសវិបត្តិជំងឺឆ្លងជាសកលនេះ ដែលមូលហេតុតែម្យ៉ាងគត់នៃការធ្លាក់ចុះចំណូល។ ជាលទ្ធផល ពួកគាត់បានព្យាយាមកាត់បន្ថយការចំណាយ និងបានខ្ចីប្រាក់ពីសាច់ញាតិ ដែលមិនទាមទារការប្រាក់ពីគាតើឡើយ។សម្រាប់អ្នកមានបំណុលធនាគារ ពួកគាត់បានស្វែងរកការងារជំនួសក្នុងរយៈពេលខ្លីមួយគ្រារ ដើម្បីមានប្រាក់ក្នុងការបង់។

អ្នកស្រី តុង ស្រីង៉ាន់ ដែលជាម្ចាស់សំអាងការ បានលើកឡើងថា ក្រោយពេលរដ្ឋាភិបាលសម្រេចបិទពិធីមង្គលការ ចំណូលរបស់គាត់ត្រូវបានបាត់បង់ស្ទើរតែទាំងស្រុង។ ពួកគាត់អាចរកចំណូលបានប្រហែល ១០% ពីការជួលក្នុងពិធីតូចៗដូចជា ពិធីសែន ដែលជំនួសឲ្យពិធីរៀបអាពាហ៍ពិពាហ៍ និងពិធីភ្ជាប់ពាក្យជាដើម ចំណូលនេះមិនអាចឲ្យគាត់យកមកប្រើប្រាស់បានគ្រប់គ្រាន់សម្រាប់ការចំណាយពីមួយខែទៅមួយខែបានទេ ដោយគាត់បានយកលុយដែលបានសន្សំមកប្រើប្រាស់។

# ជំពូកទី៣

# ការងើបឡើងវិញនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

## ៣.១. សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២១

រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការងារយ៉ាងល្អដើម្បីទប់ស្កាត់ការចម្លងមេរោគនេះ ព្រមទាំងគាំទ្រក្រុមប្រជាជនងាយរងគ្រោះ ក្នុងការដោះស្រាយការបាត់បង់មុខរបររបស់ពួកគេ តាមរយៈការអនុវត្តកម្មវិធីផ្ទេរសាច់ប្រាក់ ដោយផ្អែកលើប្រព័ន្ធជំនួយសង្គមរបស់ខ្លួន។ ការការពារសុខសុវត្ថិភាពពីថ្នាក់ដឹកនាំ ដើម្បីការរស់នៅរបស់ប្រជាពលមានសុភមង្គល និងសុខសាន្ត វាជាអ្វីដែលប្រជារាស្ត្រទូទៅតែងតែចង់ឃើញ និងត្រូវការវា។ ដោយសារឥទ្ធិពលនៃវិបត្តិកូវីដ១៩ មានការថមថយចាប់តាំងពីដើមឆ្នាំ២០២១មកយើងអាចមកមើលការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់កម្ពុជាយើង ដោយយោងតាមរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្ហាញថា ៖ នៅឆ្នាំ២០២១ សេដ្ឋកិច្ចមានការងើបឡើងវិញដោយកំណើនទាប ក្នុងទំហំ ២.៦% ហើយ ផសស ថ្លៃបច្ចុប្បន្នកើនដល់ ១១០ ៩៧២ ប៊ីលានរៀល ហើយ ផសស សម្រាប់មនុស្សម្នាក់ស្ថិតក្នុងអត្រា ១ ៦៦៥ ដុល្លារអាមេរិក ដែលមានអតិផរណាស្ថិតក្នុងកម្រិតគ្រប់គ្រងបានក្នុងអត្រា ២,៩% ក្នុងឆ្នាំ ២០២១ ដូចឆ្នាំ ២០២០ ដែរ ដោយសារការងើបឡើងវិញនៃថ្លៃប្រេងលើទីផ្សារអន្តរជាតិបន្ទាប់ពីប្រទេសជាច្រើនបានបើកប្រទេសឡើងវិញ ខណៈដែលបានប៉ះប៉ូវដោយការថមថយនៃថ្លៃម្ហូបអាហារ (MEF, ២០២១, *online*) ។ ទន្ទឹមនេះ អត្រាប្តូរប្រាក់បន្តមានស្ថិរភាព ក្នុងរង្វង់ប្រមាណ ៤ ០៦៨ រៀលក្នុងមួយដុល្លារអាមេរិក។

<u>ក្រាបលេខ ១ ៖ ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២១</u>




<u>ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (២០២២)</u>

ក្នុងរបាយការណ៍វាយតម្លៃកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០២១របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបន្តលើឡើងអំពីសេដ្ឋកិច្ចកម្ពុជា សម្រាប់ឆ្នាំ ២០២២ ដោយបានព្យាករថានឹងបន្តនិន្នាការកើនឡើង ក្នុងរង្វង់ ៥,៦% គាំទ្រដោយការរំពឹងទុកការកើនឡើងនៃតម្រូវការសកល និងទំនុកចិត្តរបស់វិនិយោគិនបរទេស ដែលជាសមិទ្ធផល នៃការគ្រប់គ្រងស្ថានភាពការរីករាលដាលនៃជំងឺកូវីដ-១៩ បានល្អ។ ជារួម កំណើននេះត្រូវបានទ្រទ្រង់ដោយការបន្តកំណើនល្អប្រសើរនៃវិស័យឧស្សាហកម្ម និងវិស័យកសិកម្ម និងជាពិសេសការងើបឡើងវិញនូវវិស័យសេវាកម្ម ដោយសារការរំពឹងទុកការងើបឡើងវិញនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងអនុវិស័យអចលនទ្រព្យ។ ក្នុងនោះ វិស័យឧស្សាហកម្ម ត្រូវបានព្យាករថា មានកំណើន ៨,៤% ក្នុងឆ្នាំ ២០២២ ដែលគាំទ្រដោយកំណើនល្អប្រសើរនៃអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ។ វិស័យកសិកម្ម ត្រូវបានរំពឹងថាបន្តសម្រេចបានកំណើនល្អប្រសើរ ក្នុងអត្រា ១,៣% ក្នុងឆ្នាំ ២០២២ ដោយសារការបន្តនិន្នាការល្អនៃអនុវិស័យដំណាំ និងចិញ្ចឹមសត្វ គួបផ្សំនឹងការងើបឡើងវិញនៃអនុវិស័យនេសាទ។ ទន្ទឹមនេះ វិស័យសេវាកម្ម ត្រូវបានរំពឹងថានឹងងើបឡើងវិញ ក្នុងអត្រា ៥,១% ក្នុងឆ្នាំ ២០២២ ដោយសារការងើបឡើងវិញនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងអនុវិស័យអចលនទ្រព្យ ស្របពេលដែលអនុវិស័យលក់ដុំ-រាយ និងអនុវិស័យដឹកជញ្ជូន និងគមនាគមន៍រំពឹងថាបន្តកើនឡើង។ បន្ថែមនេះ អត្រាអតិផរណា ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ ៣,0% ដោយសារការរំពឹងទុកការវិលត្រឡប់ទៅរកប្រក្រតីភាពវិញនៃសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩ ខណៈអត្រាប្តូរប្រាក់ ត្រូវបានរំពឹងថានៅស្ថិតក្នុងរង្វង់ ៤ ០៦៥ រៀលក្នុងមួយដុល្លារអាមេរិក។

គួរកត់សម្គាល់ផងដែរថា កាលពីដើមខែសីហា ឆ្នាំ២០២១ ក្រុមប្រឹក្សាភិបាលនៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានអនុម័តការវិភាជថវិកាទូទៅមួយពីគណនីមូលនិធិពិសេស (SDRs) ជាប្រវត្តិសាស្ត្រ ដែលស្មើនឹង ៦៥0 ពាន់លានដុល្លារ ស.រ. ដើម្បីជម្រុញលទ្ធភាពទូទាត់ការចំណាយរបស់សកលលោក។ កម្ពុជានឹងទទួលបានចំនួន 0,២៤ពាន់លាន ដុល្លារ សហរដ្ឋអាមេរិច ។ SDRs នឹងជួយប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងកម្ពុជាផងដែរ ដើម្បីដោះស្រាយផលប៉ះពាល់នៃជំងឺកូវីដ-១៩ និងស្តារសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ។

## ៣.២. និន្នាការពន្លឿននៃដំណើរការការងារ និងមុខរបរក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្រោយការបើកប្រទេសឡើងវិញ ក្នុងអំឡុង ១ខែ ដំបូង

វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធចាប់ផ្តើមបើកដំណើរការឡើងវិញជាបន្តបន្ទាប់ហើយ ក្រោយរដ្ឋាភិបាលប្រកាសបើកប្រទេសឡើងវិញកាលពីថ្ងៃទី១ ខែវិច្ឆិកាមក។ ចំពោះការបើកសេដ្ឋកិច្ចឡើងវិញនេះ វាជាការសាទរយ៉ាងខ្លាំងសម្រាប់ធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រោះពួកគេបានបាត់ចំណូល ឬមុខរបរអស់រយៈពេល ២ឆ្នាំហើយ ចាប់តាំងពីដើមឆ្នាំ២០២០ រហូតដល់ចុងឆ្នាំ២០២១ ដែលក្នុងរយៈពេល២ឆ្នាំនោះ ពួកគេបានបាត់បង់ប្រាក់ចំណូល និងមុខរបរមួយចំនួនត្រូវបានដួលរលំ។ បើយោងតាម Rfi (2021) បានធ្វើការរៀបរាប់ពីស្ថានភាពនៃការដំណើរការមុខរបរក្នុងរយៈពេល ៣ សប្តាហ៍ដំបូងនៃការបើកឡើងវិញ ដែលបានសង្កេតឃើញថាដំណើរការការងារ និងមុខរបរក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មិនទាន់ល្អទេ។ បើគិតជាភាគរយវិញគឺទើបបានតែ ៦០% តែប៉ុណ្ណោះ ដោយសារអាជីវករមួយចំនួនមានការខាតបង់ប្រាក់ចំណូលច្រើន មុខរបរត្រូវបានដួលរលំ សម្ភារៈ ឬទ្រព្យសម្បត្តិរបស់ពួកគាត់មួយចំនួនបានដាក់បញ្ចាំ ឬលក់ ដើម្បីយកមកផ្គត់ផ្គង់ជីវភាពរស់នៅក្នុងគ្រួសារ។ ដូច្នេះ ក្រោយពេលបើកប្រទេសក្នុងរយៈ ៣ សប្តាហ៍ គឺអ្នកមានលទ្ធភាព ឬរងផលប៉ះពាល់តិចតួចក៏បើកទៅ ហើយសម្រាប់អ្នករងផលប៉ះពាល់ខ្លាំង ពួកគាត់ខិតខំស្វែងរកមធ្យោបាយ ក្នុងការដំណើរការមុខរបរឡើងវិញ ដោយការខ្ចីលុយពីធនាគារ ខ្ចីបុលពីសាច់ញាតិ ។ល។

គួរកត់សម្គាល់ថា ក្នុងពេលដំណើរការដំបូងនេះ អតិថិជនដែលមកទិញទំនិញ ឬសេវាកម្មមិនមានចំនួនច្រើនដូចកាលមិនទាន់មានវិបត្តិកូវីដ១៩ ទេ។ សម្រាប់អាជីវករក្រៅប្រព័ន្ធនៅតំបន់ទេសចរ ពួកគាត់នៅមិនទាន់បានទទួលភ្ញៀវទេសចរបរទេសដូចពីមុខទេ ពួកគាត់នៅតែជួបភាពលំបាក ប៉ុន្តែវាប្រសើរជាងមុខបន្តិច។ សម្រាប់អ្នកប្រកបមុខរបរដឹកភ្ញៀវដូចជា អ្នករត់ Pass up, ម៉ូតូឌុប, ឡានតាក់ស៊ី ក៏មិនទាន់មានភាពប្រសើរឡើងខ្លាំងដែរ ពោលគឺពួកគាត់នៅមានផលលំបាកត្រង់ការព្រួយបារម្ភរបស់ភ្ញៀវចំពោះការឆ្លង មានន័យថាពួកគាត់មិនទាន់ប្រើប្រាស់សេវាកម្មទាំងនោះទេ ដោយពួកគេប្រើប្រាស់យានជំនិះផ្ទាល់ខ្លួន។ ចំពោះបញ្ហាបំណុលធនាគារវិញ វាជារឿងរ៉ាវដែលធ្វើឲ្យពួកគាត់មានសម្ពាធយ៉ាងខ្លាំង ហើយក្នុងរយៈខ្លីនៃការបើកដំណើរមុខរបរឡើងវិញនេះ ពួកគាត់នៅមិនទាន់មានលទ្ធភាពក្នុងការសងបំណុល បើទោះបីជាមានការពន្យារពេលសង ឬបន្តការខ្ចីបន្ថែម ព្រោះការធ្វើនេះមិនឆ្លើយតបទៅនឹងតម្រូវការ ភាពចំណេញ ឬភាពដោះទាល់របស់ពួកគាត់នៅឡើយ។

ស្រុកសំរោង មានសក្តានុពលដ៏សំខាន់សម្រាប់សេដ្ឋកិច្ចក្នុងខេត្តតាកែវ ដោយមានទាំងតំបន់ទេសចរណ៍ (រមនីយដ្ឋានភ្នំជីសូរ) ផ្ទៃដីដាំដុះដំណាំស្រូវប្រាំងនិងវស្សាដ៏ធំល្វឹងល្វាយ មានរចនាសម្ព័ន្ធផ្លូវថ្នល់ សាលារៀន មន្ទីពេទ្យ ដ៏ច្រើនសម្រាប់បំពេញតម្រូវការរបស់ប្រជាពលរដ្ឋទាំង ១២៩,២១៤ នាក់(២០២២)។ នៅថ្ងៃទី១៥ ឧសភា ឆ្នាំ២០២២ បើយោងតាមរបាយការណ៍របស់រដ្ឋបាលស្រុកសំរោង ខេត្តតាកែវបានឲ្យដឹងថា ក្នុងចំណោមប្រជាជនទាំង ១២៩,២១៤ នាក់នេះ មានអ្នកឆ្លងសរុប ៧៧៧ នាក់ អ្នកសះស្បើយ ៧៤១ នាក់ អ្នកបន្តព្យាបាល ០០ នាក់ និងអ្នកស្លាប់ចំនួន ៣៦ នាក់។ ក្រោយវិបត្តិកូវីដ១៩ធូរស្រាល និងអត្រាខ្ពស់នៃការទទួលវ៉ាក់សាំងរបស់ប្រជាពលរដ្ឋនេះ ស្ថានភាពសេដ្ឋកិច្ចជាទូទៅនៅក្នុង ស្រុកសំរោង ខេត្តតាកែវ មានភាពល្អប្រសើរឡើងវិញ យើងឃើញថា៖ ភាពអ៊ូរអរនៅតាមទីប្រជុំជន ជាពិសេសនៅតាមបណ្តាលផ្សារបត់រកាផ្សារយាយគ្រប់ ផ្សារស្វាយព្រៃ និងផ្សារថ្នល់ទទឹង បានធ្វើអាជីវករក្រៅប្រព័ន្ធសេដ្ឋកិច្ចអាចស្វែងរកប្រាក់ចំណេញឡើងវិញ ប៉ុន្តែមិនដូចការលក់ដូរការមុនមានវិបត្តិនេះទេ គ្រាន់តែប្រសើរជាងកាលលក់ដូរក្នុងវិបត្តិ។

**ប្រអប់លេខ ៤៖ ការងើបឡើងវិញនៃប្រាក់ចំណូលរបស់អាជីវករសំណាក់**

ការសម្ភាសន៍ជាមួយអ្នកស្រី សុខ សុខុន ដែលជាម្ចាស់ផ្ទះសំណាក់មួយកន្លែង មានទីតាំងនៅរមនីយដ្ឋានភ្នំជីសូរនៃស្រុក សំរោងខេត្តតាកែវបានឲ្យដឹងថា គាត់ត្រូវចំណាយថ្លៃទឹកភ្លើង ដែលវាជាចំណាយប្រចាំខែរបស់គាត់ ដោយរកចំណូលក្នុងសម័យកូវីដ១៩ មកទូទាត់នឹងថ្លៃទឹកភ្លើងសឹងមិនគ្រប់ផង។ ចំណូលរបស់គាត់ក្នុងសម័យកូវីដ១៩ មានចន្លោះពី ៣០% ទៅ ៥០% ពោលគឺនៅក្រោមកម្រិក ៥០% ទៅទៀត។ គួរកត់សម្គាល់ថា មុខពេលកើតមានវិបត្តិសេដ្ឋកិច្ចនេះ គាត់បានពង្រីកអាជីវកម្មរបស់គាត់ ដោយបានសាងសង់ផ្ទះសំណាក់ធំថ្មីមួយ ដែលមានកំពស់ ៣ ជាន់។ ក្រោយពេលចំណាយជាច្រើនសម្រាប់ទទួលភ្ញៀវក្នុងតំបន់ទេសចរណ៍នោះ ចូលមកដល់ដើមឆ្នាំ២០២០ បែរជាមិនមានភ្ញៀវទៅវិញ វាបានធ្វើឲ្យមានសម្ពាធផ្លូវចិត្តចំពោះប្រាក់ចំណូល ចំណាយ និងបំណុល។

ក្រោយពេលរដ្ឋាភិបាលសម្រេចឲ្យបើកពិធីនានា និងទេសចរណ៍ឡើងវិញ គាត់អាចរកចំណូលបានចន្លោះពី ៥០% ទៅ ៨០% នៃចំណូលដែលធ្លាប់រកបានពីមុខកូវីដ១៩។ គាត់បានបញ្ជាក់ថា ចំណូលរបស់គាត់បានកើនឡើងវិញជាបន្តបន្ទាប់ បន្ទាប់ពីកម្ពុជាសម្រេចបើកពិធីរៀបអាពាហ៍ពិពាហ៍ បុណ្យ និងតំបន់ទេសចរណ៍ ដែលវាធ្វើឲ្យគាត់ទទួលបានភ្ញៀវមកពីចម្ងាយមកទទួលសេវាកម្មនៅកន្លែងគាត់។ គាត់បានលើកឡើងថា ចាប់តាំងពីកម្ពុជាបានប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរនៅឆ្នាំ២០២២នេះមក គាត់មានភ្ញៀវជាច្រើនមកជួលបន្ទប់គេងរបស់គាត់។

តាមការរៀបរាប់របស់លោក ជា វ៉ាន់យុទ្ធ (២០២១) បានឲ្យដឹងថា កម្ពុជា កំណើនតម្រូវការអគ្គិសនីនឹងកើនឡើងច្រើន ដើម្បីឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ចដែលងើបឡើងវិញ នៅពេលដែលជំងឺរាតត្បាតកូវីដ-១៩ បញ្ចប់។ តម្រូវការអគ្គិសនីការកើនឡើងពី ១៥% នៅឆ្នាំ២០២០ មក ២៣% នៅឆ្នាំ២០២១។ បើយើងក្រឡេកទៅមើលសេដ្ឋកិច្ចសកលលោកដែលបានងើបឡើងវិញ ក៏មានការរីកចម្រើនផងដែរដោយយើងពិនិត្យលើតម្រូវការអគ្គិសនីសម្រាប់សេដ្ឋកិច្ចរបស់ពួកគេ។ យោងតាម គួច គន្ធារ៉ា នៅលើគេហទំព័រពត៌មានវិទ្យុបារាំងអន្តរជាតិ បានឲ្យដឹងថា ៖ វិបត្តិសេដ្ឋកិច្ចដែលបង្កឡើងដោយវិបត្តិកូវីដ១៩ បានធ្វើឲ្យតម្រូវការអគ្គិសនីលើពិភពលោកក្នុងឆ្នាំ ២០២០ ធ្លាក់ចុះចំនួន ២% ដែលនេះជាព្រឹត្តិការណ៍មួយដែលមិនធ្លាប់ឃើញតាំងពីពាក់កណ្តាលសតវត្សទី២០។ ជាការប្រៀបធៀប តម្រូវការអគ្គិសនីបានធ្លាក់ចុះប្រមាណតែ 0,៦% ប៉ុណ្ណោះក្នុងឆ្នាំ ២០០៩ ដែលពិភពលោកបានធ្លាក់ក្នុងវិបត្តិហិរញ្ញវត្ថុ។ ខណៈពេលដែល ចិននៅជាប្រទេសដែលបន្តត្រូវការអគ្គិសនីក្នុងឆ្នាំ ២០២០ ជាមួយនឹងកំណើន ២%។ តែអត្រានេះទាបខ្លាំង បើធៀបនឹងប៉ុន្មានឆ្នាំចុងក្រោយនៅមុនផ្ទុះវិបត្តិកូវីដ១៩។ សម្រាប់ឆ្នាំ ២០២១ ជាមួយនឹងការងើបឡើងវិញនូវសេដ្ឋកិច្ចសកល ពិសេសសន្ទុះកំណើនសេដ្ឋកិច្ចក្នុងប្រទេសចិន និងឥណ្ឌា ពីកំណើនតម្រូវការអគ្គិសនីក្នុងលោកប្រមាណជា ៣%។ តែអត្រាកំណើន ៣% នេះនៅមានកម្រិតតិចតួច បើធៀបនៅក្រោយវិបត្តិហិរញ្ញវត្ថុសកលក្នុងឆ្នាំ ២០១០ ដែលតម្រូវការអគ្គិសនីបានហាក់ឡើងដល់ទៅ ៧,២%។

### ៣.៣. ការងើបឡើងវិញយ៉ាងឆាប់រហ័សនៃវិស័យទេសចរណ៍ ដែលជាជាកត្តាជំរុញដ៏សំខាន់សម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

យើងបានដឹងហើយថា វិស័យទេសចរណ៍ គឺជាវិស័យទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេក្នុងអំឡុងវិបត្តិនៃជំងឺកូវីដ១៩។ ការធ្លាក់ចុះយ៉ាងគំហុកនៃចំនួនភ្ញៀវទេសចរអន្តរជាតិ បានធ្វើឲ្យអាជីវកម្មទេសចរណ៍ជាច្រើនបានផ្អាកដំណើរការ បណ្តាលឲ្យបុគ្គលិករាប់ម៉ឺននាក់បាត់បង់ការងារ និងអ្នកដែលពឹងផ្អែកលើវិស័យនេះក្នុងការទទួលទានជាច្រើនបាត់បង់ចំណូល។ ទោះជាយ៉ាងនេះក្តី បើតាមការរាយការណ៍របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២១) បានបង្ហាញថា ៖ ចាប់ពីត្រីមាសទី ៣ ឆ្នាំ ២០២១ មានការកើនឡើងភ្ញៀវទេសចរណ៍ក្នុងស្រុក អាចប៉ះប៉ូវមួយផ្នែកដល់ការធ្លាក់ចុះនៃភ្ញៀវទេសចរអន្តរជាតិបន្ទាប់ជំងឺកូវី១៩ បានស្រាកស្រាន្ត។ ក្នុងគន្លងនៃប្រក្រតីភាពថ្មី ឥរិយាបថក្នុងការធ្វើដំណើរកំសាន្តរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិនឹងមានការប្រែប្រួលមួយចំនួន ដូចជា៖ និន្នាការងាកមករកការធ្វើដំណើរកំសាន្តក្នុងប្រទេសរបស់ខ្លួន ឬប្រទេសជិតខាងក្នុងតំបន់, ការធ្វើដោយឯករាជ្យ ឬបែបក្រុមគ្រួសារ, ការបង្វែរមករក

ផលិតផលទេសចរណ៍បៃតងនៅតំបន់អេកូទេសចរណ៍ជាជាងរមណីយដ្ឋានប្រវត្តិសាស្ត្រ, ការប្រុងប្រយ័ត្នក្នុងការចាយ និងធ្វើផែនការច្បាស់លាស់មុនធ្វើដំណើរ, និន្នាការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការកក់ និងទូទាត់ប្រាក់ ជាពិសេសការយកចិត្តទុកដាក់លើសុខភាព និងសុវត្ថិភាព។

គួរឲ្យកត់សម្គាល់ថា មានព្រឹត្តិការណ៍ពីរ ដែលបង្ហាញពីការងើបឡើងវិញនៃភ្ញៀវទេសចរណ៍។ ទី១, ពិធីបុណ្យអុំទូកនៅខែវិច្ឆិការ ឆ្នាំ២០២១ដែលជាពេលក្នុងការដាក់ឲ្យសាកល្បងអំពីកម្រឹតនៃការរីករាលដាលនៃជំងឺកូវីដ១៩ ក្នុងសហគមន៍ បើយោងតាមការចុះផ្សាយរបស់ខ្មែរថាមស៍ដែលសរសេរដោយ យឹម ស្រីលីន (២០២១) បានឲ្យដឹងថា ៖ ប្រជាពលរដ្ឋជាង ៩០ ម៉ឺននាក់រួមទាំងជនបរទេស ១០.០០០នាក់ បានធ្វើដំណើរជុំវិញប្រទេសកម្ពុជា ក្នុងឱកាសបុណ្យអុំទូករយៈពេលបីថ្ងៃ ក៏ដូចជាទៅលេងខេត្ត និងតំបន់ទេសចរណ៍នានា។ ការកើនឡើងនៃការធ្វើដំណើររបស់ប្រជាជន គឺជាសញ្ញានៃទំនុកចិត្តនៅក្នុងយុទ្ធនាការចាក់វ៉ាក់សាំងរបស់ប្រទេស ដែលបានចាក់វ៉ាក់សាំងដល់ប្រជាជនចំនួនពីរដងដោយជោគជ័យទៅដល់ជាង ៨៨ ភាគរយនៃចំនួនប្រជាជនសរុប។ យុទ្ធនាការនេះបានក្លាយជាទំនោរនៃការស្តារវិស័យទេសចរណ៍ដើម្បីជំរុញទេសចរណ៍ចូលមកកម្ពុជាឡើងវិញ។និងទី២, ពិធីបុណ្យចូលឆ្នាំខ្មែរ, រយៈពេល២ឆ្នាំ ជាប់ៗគ្នាមកហើយ ដែលពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិរបស់ខ្មែរយើងត្រូវបានអាក់ខានមិនឱ្យមាន ការជួបជុំ ប្រមូលផ្តុំមនុស្សច្រើនកុះករ តែពិធីទទួលទេវតា នៅតែធ្វើទៅតាមប្រពៃណីទំនៀម ទម្លាប់នៅតាមផ្ទះរៀងៗខ្លួន ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ តាមការណែនាំរបស់រាជរដ្ឋាភិបាល ។ ប៉ុន្តែសម្រាប់ឆ្នាំ ២០២២ នេះ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរយើងត្រូវបានរាជរដ្ឋាភិបាល អនុញ្ញាតឱ្យ ធ្វើពិធីនិងមានការជួបជុំកម្សាន្តសប្បាយជាធម្មតា (គង់,២០២២, *online*) ។ ដោយផ្អែកលើការរាប់របស់កញ្ញា អោ ស្រីពេជ្រ (RFI, 2022, *online*) បានកំណត់សម្គាល់ថា ៖ របាយការណ៍ភ្ញៀវទេសចរកម្សាន្តក្នុងគំឡុងពេលពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិនៅឆ្នាំ២០២២នេះ មានសរុបជិត ៤លាន៦សែននាក់ ក្នុងនោះ មានភ្ញៀវជាតិជាង ៤លាន៥សែននាក់ និងភ្ញៀវបរទេសផ្ទៃក្នុងជិត៣ម៉ឺននាក់ ដែលចំនួននេះវាប្រហាក់ប្រហែលនឹងភ្ញៀវចេញកម្សាន្តពិធីបុណ្យចូលឆ្នាំខ្មែរកាលពីមុនវិបត្តិកូវីដឆ្នាំ២០១៩ដែរ។ ខណៈពេល ការធ្វើដំណើរអន្តរជាតិត្រូវបានសម្របសម្រួលបន្ថែមទៀតដោយការដាក់ឱ្យប្រើប្រាស់ឡើងវិញនូវកម្មវិធី ទិដ្ឋការនៅពេលមកដល់និងការដកចេញវិធានការធ្វើតេស្តកូវីដនៅក្នុងខែមីនា ឆ្នាំ២០២២ មុនពេលមកដល់កម្ពុជា ដែលជួយសញ្ញាវិជ្ជមានសម្រាប់សេដ្ឋកិច្ចកម្ពុជា (ខ្មែរថាមស៍, ២០២១, *online*)។

កាលណាមានកំណើនភ្ញៀវទេសចរណ៍កាន់តែច្រើន មានន័យថា ៖ អ្នករកស៊ីក្នុងវិស័យសេដ្ឋកិច្ចក្រៅដែលពឹងផ្អែកលើវិស័យទេសចរណ៍នេះក៏មានកំណើនចំណូលដែរ ជាមួយនឹងអ្នកទៅកំសាន្តនៅតំបន់ទេសចរណ៍របស់ពួកគេ។ ប្រអប់លេខ ៥ ខាងក្រោមនេះ គឺជាការបង្ហាញពីកំណើនភ្ញៀវទេសចរនៅរមណីយដ្ឋានប្រវត្តិសាស្ត្រភ្នំជីសូរ។

**ប្រអប់លេខ ៥៖ អាជីវករលក់ដូរនៅរមនីយដ្ឋានភ្នំជីសូរមានភ្ញៀវឡើងវិញ**

អ្នកស្រី ហ៊ុំ ស្រីលក្ខណ៍ ដែលជាអ្នកលក់នៅតាមចិញ្ចើមផ្លូវឡើងទៅលើភ្នំជីសូរ បានផ្តល់ការសម្ភាសន៍ដោយគាត់បានលើកឡើងថា "សម្រាប់ការលក់ដូររបស់មីង អំឡុងពេលប្រារព្ធពិធីបុណ្យអុំទូកដែលមានវត្ត ឬ តំបន់ទេសចរណ៍ដទៃបានរៀបចំការប្រឡងប្រណាំងទូក ដោយមានអ្នកដើរលេងច្រើនគួរសមមកទស្សនារមនីយដ្ឋានភ្នំជីសូរ។ ពេលនោះ ខ្ញុំបានលក់ដាច់មជ្ឈូរ នំនេក និងភេសជ្ជៈផ្សេងៗ ដោយមានចំនួនប្រហែល ២០ ម៉ឺន សម្រាប់ថ្ងៃទី២។" គាត់បានបន្តទៀតថា ចំនួននេះ វាស្មើនឹង៥០% កាលការប្រារព្ធពិធីបុណ្យនេះនៅក្នុងឆ្នាំ២០១៨ ប៉ុន្តែវាមានកំណើនបើធៀបជាមួយចំណូលដែលអាចរកបានក្នុងសម័យកូវីដ១៩។

អ្នកស្រី ហ៊ុំ ស្រីលក្ខណ៍ បង្ហាញថាចំណាប់អារម្មណ៍ពីការលក់ក្នុងអំឡុងពិធីបុណ្យចូលឆ្នាំខ្មែរថា "ខ្ញុំ ក៏ដូចជាអ្នកលក់ដទៃទៀតនៅទីនេះ ពិតជារីករាយខ្លាំងណាស់នៅពេលមានភ្ញៀវទេសចរណ៍មកពីភ្នំពេញ និងជាពិសេសអ្នកខេត្តតាកែវ មកកំសាន្តនៅរមនីយដ្ឋានរបស់ពួកយើង គាត់លក់សឹងមិនទាន់ដោយឲ្យអ្នកនៅរងចាំ ហើយក៏មានភ្ញៀវខ្លះ គាត់មិនអាចឈរចាំ ដែលបានទៅរកទិញនៅកន្លែងផ្សេង។" អ្នកលក់ដទៃទៀតក៏លក់ដាចខ្លាំងប្រហាក់ប្រហែលគ្នានឹងកន្លែងអ្នកស្រីដែរ។

ដោយឡែក លោក ពូរ៉ា ដែលជាអ្នកស៊ីឈ្នួលក្នុងការដឹកជញ្ជូនអីវ៉ាន់ពីខាងក្រោមយកទៅលើកំពូលភ្នំជីសូរទៅដល់កន្លែងអ្នកលក់ ក៏បានបង្ហាញអារម្មណ៍រីករាយជាខ្លាំង នៅពេលគាត់អាចចំណូលបានច្រើនមកវិញ ក្រោយខកខានជាង១ឆ្នាំ ក្នុងវិបត្តិកូវីដ១៩។ គាត់បាននិយាយថា "ក្នុងមួយថ្ងៃ ខ្ញុំអាចរកចំណូលទាំងអស់ដោយគិតពីការចំណាយលើសាំង និងអាហារពីរពេលរួច ប្រហែលជា ៧ ទៅ ៨ ម៉ឺនរៀល។" គួរបញ្ជាក់ថា ចាប់តាំងពីការប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរមក មានភ្ញៀវទេសចរជិតឆ្ងាយមកកំសាន្តលេងនៅរមនីយដ្ឋានជាហូហែរ ជាពិសេសនៅថ្ងៃចុងសប្តាហ៍ដែលពួកគាត់អាចរកចំណូលបានច្រើន។

## ៣.៤. កំណើននៃការតម្រូវការ

ជាការពិតណាស់ យុទ្ធសាស្ត្រ "រស់នៅជាមួយកូវីដ-១៩" បានបង្កលក្ខណៈឲ្យសេដ្ឋកិច្ចមានដំណើរការឈានទៅស្តារស្ថានភាពឡើងវិញ។ រាល់វិស័យទាំងឡាយបានដំណើរការធម្មតាឡើងវិញ នោះក៏មានន័យថា តម្រូវការប្រើប្រាស់ក្នុងសេដ្ឋកិច្ចនឹងមានការកើនឡើងយ៉ាងឆាប់រហ័ស ដែលវានិន្នាការទៅរកភាពដើមវិញ។ គួបញ្ជាក់ថា បើតាមច្បាប់នៃឥរិយាបថរបស់អ្នកប្រើប្រាស់ទៅលើប្រភេទទំនិញ នៅពេលដែលចំណូលថយចុះ នោះនឹងនាំឲ្យកើនឡើងនៃតម្រូវការទំនិញ "ថោក (សន្មត)" (inferior good) ហើយនៅពេលចំណូលកើនឡើង ពួកគេតែចង់មានតម្រូវការលើទំនិញ "ធម្មតា (សន្មត)" (normal good)។ ដូច្នេះ យើងអាចនិយាយបានថា នៅក្នុងអំឡុងពេលមានវិបត្តិកូវីដ១៩ អ្នកប្រើប្រាស់មាននិន្នាការប្រើប្រាស់ដែលមានតម្លៃជាងមុនពេលកើតមានវិបត្តិកូវីដ១៩ វាឱកាសសម្រាប់អាជីវកម្មក្រៅប្រព័ន្ធដែលលក់ទំនិញធូរថ្លៃជាងអាជីវកម្មក្នុងប្រព័ន្ធ។ ឧទាហរណ៍ ការប្តូរពីការញ៉ាំកាហ្វេការហាង មកញ៉ាំកាហ្វេនៅតាមចញ្ចើមផ្លូវ។ ប៉ុន្តែសម្រាប់អ្នកដែលមានចំណូលនៅក្រោមបន្ទាត់ក្រីក្រដែលមានចំនួន ១៧.៨% នៃប្រជាជនកម្ពុជាសរុបនៅទូទាំងប្រទេស កំពុងរស់ក្រោមបន្ទាត់ភាពក្រីក្រ (អេា, ២០២១, *online*) ដែលជាមូលហេតុនាំឲ្យពួកគេមិនអាចមានលទ្ធភាពក្នុងការទំនិញចាំបាច់មកប្រើប្រាស់បាន។ហើយនៅពេលដែលសេដ្ឋកិច្ចលែងត្រូវបានគម្រាមកំហែងដូចជាពេលបច្ចុប្បន្ន វាជាពេលដែលពួកគាត់អាចរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ និងអាចចេញផុតពីបន្ទាប់ក្រីក្រ។ កាលណាពួកគេរកចំណូលបានកាន់ច្រើនដូចនៅពេលវិបត្តិកូវីដ១៩នេះថមថយ មានន័យថាតម្រូវការនៅលើទីផ្សារក៏មានការកើនឡើងដែរ ដោយសារពួកគេមានលទ្ធភាពក្នុងការបំពេញកាតព្វកិច្ចចំពោះការទិញលក់។ បើតាមការពិនិត្យ និងអង្កេតនៅក្នុងតំបន់ស្រាវជ្រាវបានឲ្យដឹងថាសន្ទុះនៃការប្រើប្រាស់លើទំនិញទូទៅមានល្បឿនលឿនគួរឲ្យកក់សម្គាល់។

| ប្រអប់លេខ ៦៖ ការផ្គត់ផ្គង់របស់អាជីវករទាំង២១រូប មានការកើនឡើង |
|---|
| ឆ្លងកាត់ការសម្ភាសន៍ជាមួយអាជីវករក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធទាំង ២១ នាក់ បានបង្ហាញថា ពួកគាត់មានអតិថិជនកើនពីមួយខែទៅមួយខែ ជាមួយនឹងកំណើនចំណូលរបស់ពួកគេ។ សម្រាប់ត្រីមាសទី៣ ក្នុងឆ្នាំ២០២២នេះ សម្រាប់អាជីវកម្មខ្លះទទួលបានចំណូលចន្លោះពី ៧៥% ទៅ ៩៥% ខណៈដែលអាជីវកម្មខ្លះទៀតមានប្រាក់ចំណូលកើនឡើងពីចន្លោះពី ១០៥% ទៅ ១៥០%។ ពួកគេពិតជាសាទរយ៉ាងខ្លាំងក្រោយវិបត្តិកូវីដ១៩ ត្រូវបានគ្រប់គ្រង ដែលមានលក្ខណៈថមថយទៅវិញ ដែលនាំពួកបន្ត និងពង្រឹងអាជីវកម្ម ក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា។ |

អ្នកស្រី ជួង ស្រីណា មានអាយុ ៣០ឆ្នាំ រស់នៅក្នុងភូមិត្រពាំងស្រង់ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ដែលមានមុខរបរជាអ្នកលក់ចាប់ហួយនៅមុខផ្ទះ បានរៀបរាប់ឲ្យដឹងថា ការលក់ដូររបស់គាត់ក្នុងវិបត្តិកូវី១៩ គឺមានផលប៉ះពាល់យ៉ាងខ្លាំងដោយចំណូលបានសម្រាប់តែមួយចំអែតក្រពះមួយគ្រួសារទេ ពោលគឺគាត់មានការពិបាកជាមួយនឹងការបង់បំណុលធនាគារនៅរាល់ចុងខែ។ គាត់បានលើកឡើងថា "ខ្ញុំ បានពង្រីកនូវមុខទំនិញបន្ថែមទៀត ចាប់តាំងពីចូលឆ្នាំខ្មែរមក ដោយបានបន្ថែមការលក់ម្ហូបសាច់អាំង សំល្លពីរបីមុខ ពងទារកូន និងអាហារមួយចំនួនផ្សេងទៀត ក្រោយពីការគាំទ្រពីអ្នកទិញក្នុងនិងក្រៅភូមិ ហើយក៏អ្នកដំណើរពីចម្ងាយបានចូលទិញអាហារទាំងនេះដែរ។" គាត់បន្ថែមទៀតថា "នៅថ្ងៃចុងសប្តាហ៍ ខ្ញុំតែងតែលក់អស់ម្ហូបទាំងនេះ នៅមុនម៉ោង ៨ យប់ ព្រោះមានអ្នកមកទិញច្រើន ហើយម៉ូយរបស់ខ្ញុំភាគច្រើនជាកម្មកររោងចក្រ និងសំណង់។"

លោក សាន សុជាតិ មានអាយុ៣២ឆ្នាំ ជាជាងដែក និងអ្នកម៉ៅការ ដែលរស់នៅក្នុងភូមិជាមួយ ស្រីណា បានផ្តល់បទសម្ភាសន៍ដោយប្រាប់ថា ការងារនិងមុខរបររបស់គាត់មានការលំបាកណាស់ក្នុងអំឡុងពេលកូវីដ១៩វាយលុកដំបូង គឺអ្នកដែលត្រូវសាងសង់នានា និងទាក់ទងមកគាត់ ត្រូវបានរំសាយទៅវិញ ដោយសារអ្នកទាំងនោះត្រូវទុកលុយប្រើប្រាស់ក្នុងគ្រាប្រទេសកំពុងជួបទុក្ខបែបនេះ។ ក្រោយពេលប្រជាជនទូទៅអាចធ្វើការរៀនរស់ជាមួយជំងឺកូវីដ១៩នេះមក អ្នកទាក់ទងមកមានចំនួនច្រើនណាស់ ដែលគាត់និយាយថា " បច្ចុប្បន្ននេះ ខ្ញុំទទួលបានការម៉ៅការលើការផ្សារដែន ធ្វើបន្ទប់ទឹក រាប់បន្ទប់ និងការងារផ្សេងៗទៀត ប៉ុន្តែពេលខ្លះខ្ញុំធ្វើឲ្យពួកគេមិនទាន់ ហើយក៏មិនទទួលការងារពីអ្នកថ្មីថែមទៀត ព្រោះជាប់ការងារជាមួយអ្នកមុន។" គួរបញ្ជាក់ថា មិនមែនតែចំពោះលោក សុជាតិ ទេ អ្នកម៉ៅការសំណង់ដទៃជាច្រើនទៀតក៏មានកំណើនតម្រូវការយ៉ាងឆាប់រហ័សក្រោយពេលជំងឺកូវី១៩ មានការស្រាកស្រាន្ត។

# ពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវ

## ៤.១. ការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការដោះស្រាយមួយផ្នែកធំចំពោះផលវិបាកសេដ្ឋកិច្ចក្នុងសម័យកូវីដ១៩

ក្នុងបរិការណ៍ដែលពិភពលោកកំពុងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីវិបត្តិកូវីដ១៩ បច្ចេកវិទ្យាឌីជីថល ត្រូវបានមើលឃើញថាកាន់តែមានសារៈសំខាន់ ក្នុងការជួយសម្រួលដល់ដំណើរការសកម្មភាពសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ហើយថែមទាំងបានក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាព ក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ យ៉ាងណាមិញ ដោយផ្អែកតាមការសិក្សាស្រាវជ្រាវរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២១) បានឲ្យដឹងថា ៖ ការត្រៀមខ្លួនក្នុងការចាប់យកឌីជីថលរបស់កម្ពុជា ស្ថិតនៅដំណាក់កាលដំបូងនៅឡើយ ដោយកម្ពុជាស្ថិតនៅក្នុងដំណាក់កាលកំពុងបង្កើនល្បឿនចាប់យកឌីជីថលក្នុងកម្រិតទាប ដោយមានពិន្ទុ ៩.២៧ ក្នុងចំណោម ពិន្ទុសរុប ២៥ ឬឈរនៅលេងរៀងទី ១០២ ក្នុងចំណោចប្រទេស ១៤១។ ហើយការអភិវឌ្ឍទាំងរដ្ឋាភិបាលឌីជីថល ព្រោះវាជាការតាលីករដ៏សំខាន់ ក្នុងការជំរុញការចាប់យកឌីជីថលពីសំណាក់វិស័យឯកជន និងប្រជាពលរដ្ឋទូទៅ នៅមិនទាន់មានភាពប្រមូលផ្តុំនៅឡើយ ហើយភាគច្រើនមានចរិតជាកិច្ចការបណ្តោះអាសន្ន ដើម្បីដោះស្រាយបញ្ហាចំពោះមុខតែប៉ុណ្ណោះ។

យើងក្រឡេកមកលើពីអ្វីដែលឌីជីថលមានឥទ្ធិពលវិជ្ជមានមកលើសកម្មភាពសេដ្ឋកិច្ចទូទៅ ដោយការបង្ហាញពី ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (២០២១, ទំព័រទី៦) ដោយមានសក្តានុពលសំខាន់ៗរួមមាន ៖

**ការតភ្ជាប់នឹងខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃតំបន់ និង សកលៈ** ផលិតកម្មនៅក្នុងស្រុកនឹងស្ថិតក្នុងវិសាលភាពទូលំទូលាយគ្មានព្រំដែននៃបច្ចេកវិទ្យាឌីជីថល និង សម្របបាន តាមនិន្នាការសកលភាវូបនីយកម្ម តាមរយៈការតភ្ជាប់ទៅនឹងខ្សែច្រវាក់ផលិតកម្មតំបន់ និង សកល ត្រូវបានរំពឹងថា នឹងក្លាយជាមូលដ្ឋានដ៏រឹងមាំក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច។

**ការជំរុញសកម្មភាពពាណិជ្ជកម្ម និង ធុរកិច្ចៈ** ប្រសិទ្ធភាពនៃប្រតិបត្តិការទិញ-លក់ទំនិញ និង សេវាជាពិសេសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច តាមរយៈការទូទាត់កាន់តែងាយស្រួល និង រហ័ស គួបផ្សំនឹងការដឹកជញ្ជូនលឿន និង មានថ្លៃសមរម្យ នឹងត្រូវបានលើកកម្ពស់។ បម្លែមលើនេះ ការគ្រប់គ្រងអាជីវកម្ម និង

ផលិតកម្ម នឹងកាន់តែមានប្រសិទ្ធភាព ដោយសារការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល បូកផ្សំនឹងកម្លាំងពលកម្មប្រកបដោយជំនាញ។

**ការបង្កើនការងារ ជំនាញ និងវិនិយោគ៖** ការងារ និងកម្រិតជំនាញ ត្រូវបានរំពឹងថា នឹងកើនឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃទីផ្សារ តាមរយៈយន្តការរដ្ឋ តួយ៉ាង កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និង ការបណ្តុះបណ្តាលជំនាញបន្ថែមដោយវិស័យឯកជន។ ជាមួយគ្នានេះ ការលើកកម្ពស់សហគ្រិនភាព និង នវានុវត្តន៍ នឹងរួមចំណែកក្នុងការបង្កើនធុរកិច្ចថ្មី និង ការទាក់ទាញការវិនិយោគ នៅក្នុងស្រុក និង ក្រៅស្រុក នៅក្នុងវិស័យទូរគមនាគមន៍។

**ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ៖** សម្រាប់វិស័យសាធារណៈ ការផ្តល់សេវាសាធារណៈត្រូវបានរំពឹងថា នឹងមានប្រសិទ្ធភាពកាន់តែប្រសើរ និង តម្លាភាពកាន់តែខ្ពស់ តាមរយៈការទទួលយកផ្នត់គំនិតឌីជិថល និង ការលើកកម្ពស់សមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ។ និន្នាការនេះក៏បានបង្កើនឱកាសសម្រាប់ការដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ នៅក្នុងវិស័យប្រពៃណី រួមទាំងវិស័យសេដ្ឋកិច្ច សង្គម និង សន្តិសុខ។

បើពិនិត្យមកមើលការប្រើប្រាស់ឌីជិថលរបស់ប្រជាពលរដ្ឋ និងជាពិសេសក្រុមអាជីវករមួយចំនួននៅក្នុងស្រុកសំរោង ខេត្តតាកែវវិញ តាមការស្រាវបានបង្ហាញថា សកម្មភាពសេដ្ឋកិច្ចរបស់ពួកគេត្រូវបានគាំទ្រ និងមានការអភិវឌ្ឍគួរឲ្យភ្ញាក់ផ្អើលដូចបានបង្ហាញនៅក្នុងប្រអប់ទី .... ។ លើសពីនេះទៅទៀតនោះ គឺប្រព័ន្ធឌីជីថលក៏មានសក្តានុពលដល់វឌ្ឍនភាពសង្គមផងដែរ ដោយសារមនុស្សទូទៅក្នុងស្រុកនេះមានការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងការប្រាស្រ័យទាក់ទងរវាង បុគ្គល ក្រុមគ្រួសារ និង សហគមន៍។ ក្រៅពីនេះ ពួកគេតែងតែប្រើវាក្នុងការទទួលការកំសាន្ត និងទទួលបានពត៌មានពីសង្គម។

**ប្រអប់លេខ ៧៖ ការប្រើប្រាស់ឌីជីថលក្នុងអាជីវកម្មរបស់អ្នកគ្រូ យុន ស្រីនា**

អ្នកគ្រូ យុន ស្រីនា មានអាយុ ២៨ឆ្នាំ ជាគ្រូបង្រៀននៅវិទ្យាល័យសម្តេចឪ នៅក្នុងស្រុកសំរោង ខេត្តតាកែវ ហើយគាត់ក៏មានមុខរបររកស៊ីផងដែរ ដោយមានការលក់ផលិតផលថែរសម្រស់នៅផ្ទះរបស់គាត់។ គាត់បានរៀបរាប់ថា "មុខដំបូង ខ្ញុំមានគំនិតក្នុងការស្វែងរកប្រាក់បន្ថែមលើការងាររដ្ឋ ហើយខ្ញុំបានឃើញមានសំទុះនៃការលក់ផលិតផលនេះ នៅលើបណ្តាញសង្គមយ៉ាងខ្លាំង ស្របពេលដែលនៅក្នុងភូមិ

អ្នកគ្រូមិនមានអ្នកលក់នៅឡើយ បានជំរុញឲ្យខ្ញុំជ្រើសរើសវាមកសម្រាប់ការចាប់រកស៊ីមុនដំបូង ដោយធ្វើការកាត់ស្តុកមកពីភ្នំពេញតាមរយៈអ្នកស្គាល់គ្នា។ ការលក់ក្នុងខែដំបូង គឺមានតែអ្នកក្នុងភូមិ និងមិត្តភ័ក្ត្រ បានជួយទិញ បន្ទាប់មកដោយចង់ផ្សព្វផ្សាយពីផលិតនេះទៅដល់អ្នករស់នៅឆ្ងាយៗ ក៏បានចាប់ផ្តើមផ្សព្វផ្សាយក្នុងប្រព័ន្ធសង្គម លុះក្រោយក៏ចេះតែមានអ្នកស្គាល់ គេចេះតែបញ្ជាទិញជាប្រចាំ។" នេះបានបង្ហាញថា ការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងដំណើរធុរកិច្ចរបស់អ្នកគ្រូ ពិតជាមានកំណើនលក់ប្រាកដមែន។ គាត់បានបន្ថែមទៀតថា "នៅក្នុងប្រទេសកំឡុងជួបវិបត្តិកូវី១៩ កាលពីឆ្នាំ២០២០ដែលមានអាជីវកម្មជាច្រើនបានជួបនៅផលវិបាកផ្សេងៗ តែអាជីវកម្មនេះអាចរកចំណូលបានច្រើន កាលមិនទាន់មាននៅឆ្នាំ២០១៩ ដោយសារតែការប្រើប្រាស់នូវប្រព័ន្ធអ៊ីនធឺណេតមានការងាយស្រួល ហើយចំណាយអស់តិច។"

## ៤.២. អតិផរណា

ខណៈពេលដែលចំណូលរបស់ពួកចាប់ផ្តើមមានភាពប្រសើរឡើងវិញ ក្រោយវិបត្តិកូវីដ១៩ថមថយ ការចំណាយលើថ្លៃដើមក៏មានការកើនឡើងដែរ តួយ៉ាងដូចជា ការកើនឡើងជាបន្តបន្ទាប់នៃតម្លៃប្រេងឥន្ធនៈជាដើម។ យោងតាមលោក ហំ ផានិត (២០២២) បានរាយការណ៍ថា ៖ តម្លៃប្រេងឥន្ធនៈឡើងថ្លៃខ្ពស់គឺជានិន្នាការរបស់សកលលោក ជាពិសេសចាប់ពីពាក់កណ្តាលឆ្នាំ ២០២១ ក្រោយពីវិបត្តិកូវីដមានភាពធូរស្រាល ដែលធ្វើឱ្យវិស័យផលិតកម្មមានសកម្មភាពឡើងវិញ ប្រេងឥន្ធនៈចាប់ផ្តើមឡើងថ្លៃជាបន្តបន្ទាប់។ ហើយជម្លោះរវាងរុស្ស៊ីជាមួយនឹងអ៊ុយក្រែនក៏ជាបញ្ហាថ្មីមួយដែលជំរុញឱ្យតម្លៃប្រេងអន្តរជាតិនៅតែមានតម្លៃខ្ពស់ និងបន្តកើនឡើងថែមទៀត។ លោកបញ្ជាក់ថា៖ "បើសិនបញ្ហារុស្ស៊ី និងអ៊ុយក្រែននៅតែបន្ត ហើយក្រុមប្រទេស OPEC នៅតែមិនព្រមបង្កើនផលិតកម្មរបស់ខ្លួន តម្លៃប្រេងឥន្ធនៈនៅតែមិនងាយនឹងចុះវិញទេ"។ តាមរបាយការណ៍ដដែរបានបន្ថែមទៀតថា ៖ ក្នុងអំឡុងពេលវិបត្តិសង្គ្រាមនេះច្បាស់ជាមានការឆ្លៀតឱកាសថែមទៀតពីប្រទេសអ្នកផលិតប្រេងខ្លះ ក្នុងការបង្កើននូវតម្លៃប្រេងឥន្ធនៈដោយយកលេសថា ការផ្គត់ផ្គង់មិនគ្រប់គ្រាន់។ បែបនេះក្តី លោកលើកឡើងថា ទោះបីជាសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ត្រូវបានបញ្ចប់ ក៏តម្លៃប្រេងមិនអាចចុះថ្លៃបានច្រើនដែរ ដែលនេះនឹងបន្តមានផលប៉ះពាល់សម្រាប់បណ្តាប្រទេសនាំចូលប្រេងដូចជាកម្ពុជាដែលពឹងផ្អែកទាំងស្រុងលើការនាំចូលផលិតផលប្រេង 100 ភាគរយ ពីបរទេស (ខ្មែរថាមស៍, ២០២១, *online*) ដោយនឹងធ្វើឱ្យការផលិតត្រូវចំណាយថ្លៃដើមកាន់តែខ្ពស់។ ក្រៅពីប្រេងឥន្ធនៈឡើងថ្លៃ យើងឃើញថា មានការកើនឡើងនូវតម្លៃនៃទំនិញទូទៅមានដូចជា ស្បៀងអាហារគ្រប់ប្រភេទ, ទំនិញគ្រឿង

សំណង់, សេវាកម្ម ក៏ដូចជាទំនិញផ្សេងៗ បានបង្ការជាផលលំបាកយ៉ាងខ្លាំងទៅប្រជាពលរដ្ឋដែលមានចំណូលតិច ឬប្រជាជនក្រីក្រនៅក្នុងប្រទេសកម្ពុជានិយាយដោយឡែក ហើយសម្រាប់ពិភពនិយាយជារួម។

ជាមួយគ្នានេះដែរ បើឆ្លងកាត់ការសម្ភាសន៍ជាមួយអាជីវករនៅក្រៅប្រព័ន្ធទាំង ២១ រូប ក៏បានលើកឡើងពីបញ្ហាការចំណាយថ្លៃដើមខ្ពស់ផងដែរ។ បើទោះបីជា ចំណូលមានទំហំធំ តែការចំណាយក៏មានទំហំធំដែរ ដែលករណីនេះអ្នកសេដ្ឋកិច្ចហៅថា "អតិផរណា" ពោលគឺតម្លៃទំនិញកើនឡើងនឹងធ្វើឱ្យលុយធ្លាក់តម្លៃ ហើយអាចទិញទំនិញបានចំនួនតិចទៅៗ។ ជាលទ្ធផល អំណាចទិញរបស់អ្នកប្រើប្រាស់ក៏នឹងធ្លាកចុះផងដែរ។ តាមការអង្កេតមើលពីកំណើនសេដ្ឋកិច្ចនៅក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ស្ថានភាពអតិផរណាជាទូទៅនៅក្នុងប្រទេសមានភាពល្អប្រសើរ ដោយសារចំណូលកើនឡើងពី ៦ ទៅ ៧ ភាគរយ បើអតិផរណាកើនឡើងត្រឹមចន្លោះ ៣ ទៅ ៤ ភាគរយ (ណឹម & ហាន, ២០២២, *online*) ។ ប៉ុន្តែបើយោងតាមរបាយការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២២, បានឱ្យដឹងថា អតិផរណាជាមធ្យមប្រចាំត្រីមាសទី១ ឆ្នាំ២០២២ មានអត្រា ៥.៩% បើធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំមុន គឺកើនឡើងទ្វេដង ខណៈឆ្នាំមុនមានអត្រា២.១% ។ យោងតាមព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាសទី១ ឆ្នាំ២០២២ ដែលចេញផ្សាយនៅថ្ងៃទី២៧ មិថុនានេះ។ តាមរយៈទិន្នន័យនេះបង្ហាញថា អត្រាអតិផរណាក្នុងត្រីមាសទី១ នៅឆ្នាំ គឺជាអត្រាដ៏ខ្ពស់មួយដែលមិនធ្លាប់មានពីមុនមក ក្នុងរយៈពេល៧ឆ្នាំចុងក្រោយ ដោយសារតែការកើនឡើងនៃតម្លៃប្រេងសាំង ដែលបង្កឡើងដោយសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន។

# សេចក្តីសន្និដ្ឋាន

វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺនិយាយពីសកម្មភាពសេដ្ឋកិច្ចជារួម ដែលកើតឡើងដោយអង្គភាពមួយដែលដំណើរដោយគ្រួសារ ឬបុគ្គលម្នាក់ ក្នុងការស្វែងរកប្រាក់ចំណេញ គឺដើម្បីតែចិញ្ចឹមជីវិតតែមួយរស់ៗទេ ហើយរដ្ឋមិនតម្រូវឲ្យចុះបញ្ជីរទេ។ វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងប្រទេសកម្ពុជាមានការរីកចម្រើនខ្លាំងនៅពេលសេដ្ឋកិច្ចជាតិចាប់ផ្តើមងើបឡើងវិញកំឡុងឆ្នាំ២០០០ តែត្រូវបានថយចុះមកវិញនៅពេលមានកំណើរការងារក្នុងឧស្សាហកម្មកាត់ដេរ រដ្ឋបាលសាធារណៈ និងមានការងារជាច្រើនទៀតក្នុងវិស័យក្នុងប្រព័ន្ធ។ វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ចាប់ពីឆ្នាំ២០១៩ ដល់ ត្រីមាសទី៣នៃឆ្នាំ២០២២ មានភាពបត់បែនយ៉ាងខ្លាំងនៅពេលសេដ្ឋកិច្ចជាតិបានធ្លាក់ចុះ ដោយសារវិបត្តិជំងឺឆ្លងកូវីដ១៩។ ដោយនៅដើមឆ្នាំ២០២០ វិស័យនេះបានចាប់ផ្តើមទទួលរងផលប៉ះពាល់អវិជ្ជមានដោយសារភាពភ័យស្លន់ស្លោរបស់ភ្នាក់ងារសេដ្ឋកិច្ចគ្រប់គ្នា បន្ទាប់ការចេញសេចក្តីប្រកាសពីក្រសួងសុខាភិបាលពិលោកអំពីការឆ្លងជាសកល។ នៅថ្ងៃទី១៥ មេសា ឆ្នាំ២០២១ ជាថ្ងៃបិទទីក្រុងភ្នំពេញ និងក្រុងតាខ្មៅ បានធ្វើឲ្យអាជីវកម្មមួយចំនួនបានរងផលប៉ះពាល់ទាំងស្រុងដោយសារបាត់ចំណូលយ៉ាងគំហុក និងអាជីវកម្មដទៃទៀតបានរងផលវិបាកសេដ្ឋកិច្ចនៅកម្រិតស្រាល ដោយសារពួកគេមិនស្ថិតនៅក្នុងតំបន់អនុវត្តន៏វិធានការបិទខ្ទប់។ យើងឃើញថាអាជីវកម្មដែលពឹងផ្អែកលើវិស័យទេសចរណ៍មានមានការរងផលប៉ះពាល់ខ្លាំងជាងគេ នៅពេលបាត់បង់ទេសចរណ៍បរទេសម។ នៅក្នុងខែដំបូង ការចាប់ផ្តើមដំណើរអាជីវកម្មរបស់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធក៏នៅតែមានការលំបាក ដោយសារការខ្វះខាតដើមទន់សម្រាប់ដំណើរការឡើងវិញ និងអតិថិជនក្នុងពេលដំបូងនេះមានទំហំតូចជាងមុនមានវិបត្តិនេះ។ ការងើបឡើងវិញនៃវិស័យទេសចរណ៍បានធ្វើឲ្យអាជីវកម្មដែលពឹងផ្អែកលើវិស័យនេះ មានការងើបឡើងវិញយ៉ាងឆាប់រហ័ស ដោយមានចំណូលខ្ពស់ជាងការមិនទាន់មានវិបត្តិ។ ប្រព័ន្ធឌីជីថលបានចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចទាំងក្នុងនិងក្រៅប្រព័ន្ធយ៉ាងខ្លាំង តែវិស័យនេះវាទើបតែមានការរីកចម្រើននៅប៉ុន្មានឆ្នាំចុងក្រោយនេះទេសម្រាប់សេដ្ឋកិច្ចកម្ពុជា។ ស្របពេលការងើបឡើងវិញនៃសេដ្ឋកិច្ច អត្រាអតិផរណាក៏បានធ្វើឲ្យសេដ្ឋកិច្ចកម្ពុយជានិយាយផ្នែក និងសេដ្ឋកិច្ចនិយាយជារួមបានរងផលវិបាកសេដ្ឋកិច្ច ដែលវាបង្កឡើងដោយសង្គ្រាមរវាងរុស្សីនិងអ៊ុយក្រែន។

# អនុសាសន៍

ចាប់តាំងពីវិបត្តិជំងឺឆ្លងកូវីដ១៩មានការថមថយមក ទាំងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ មានការងើបឡើងវិញឆាប់រហ័ស ដែលមាននិន្នាការទៅរកស្ថានភាពដើមវិញ។ ខណៈពេលជាមួយគ្នានេះដែរ ដើម្បីបន្តអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធឲ្យមានលំនឹងមួយមួយ រាជរដ្ឋាភិបាល ក៏ដូចជាអ្នកធ្វើគោលគួរតែ ៖ ទី១, អាជ្ញាធររាជរដ្ឋាភិបាល ជាពិសេសអាជ្ញាធរថ្នាក់ក្រោមជាតិដែលទទួលបន្ទុក ត្រូវបង្ករលក្ខណៈងាយស្រួល សម្រាប់ទីតាំងនៃការប្រកបមុខរបរអាជីវកម្មរបស់អ្នកធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីឲ្យពួកគេអាចប្រកបរកស៊ីបានល្អ។ ទី២, រដ្ឋត្រូវគិតឡើងវិញនូវការផ្តល់ឥណទានណាមួយ ដែលគ្មានការប្រាក់ជូនទៅដល់អ្នកធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីមានទុនគ្រប់គ្រាន់ក្នុងការបន្ត និងពង្រីកអាជីវកម្មរបស់ពួកគាត់។ រដ្ឋត្រូវតែមានការបណ្តុះបណ្តាលជំនាញដល់ពួកគាត់បន្ថែមទៀត ដើម្បីឲ្យការគ្រប់គ្រងមុខជំនួញខ្នាតតូចរបស់គាត់ឲ្យតាមគន្លងថ្មី។ ទី៣, រដ្ឋត្រូវតែមានវិធានការយ៉ាងច្បាស់លាស់ ទាក់ទងទៅនឹងការផ្តល់ហិរញ្ញប្បទាន ដល់គ្រប់រាជធានីខេត្តក្រុងទាំងអស់ ដើម្បីឲ្យពួកគេមានឱកាសក្នុងការលក់ទំនិញ ឬផ្តល់សេវាដល់ភ្ញៀវទេសចរណ៍ផ្ទៃក្នុងឲ្យបានល្អ។ ទី៤, រដ្ឋគួរមានប្រព័ន្ធកិច្ចគាំពារសង្គមទៅដល់ពួកគេ ជាពិសេសត្រូវមានរបបសន្តិសុខសង្គមនៅពេលពួកគាត់ឈឺអាចទៅព្យាបាលនៅមន្ទីពេទ្យដោយមិនអស់ប្រាក់កម្រៃ ដែលវាជាការធានារបស់រដ្ឋាភិបាលនៅក្នុងវិស័យនេះ ដែលជាផ្នែកមួយនៃការជួយធ្វើឲ្យសេដ្ឋកិច្ចមានដំណើរការល្អផងដែរ។ ទី៥,រដ្ឋគួរតែមានគោលនយោបាយគោលមួយ ដើម្បីធានាប្រាក់ឈ្នួលនៅកម្រិតអប្បរមាចំពោះអ្នកមានការងារក្នុងក្រៅប្រព័ន្ធដូចជា ក្រុមនៃកម្មករម៉ៅការសំណង់ ឬ អ្នកធ្វើការតាមផ្ទះ ជាដើម។ វាជាកិច្ចការការពារឲ្យបាននូវប្រព័ន្ធសង្គម ដើម្បីសុវត្ថិភាពរបស់ពួកគាត់នៅពេលមានហានិភ័យណាមួយកើតឡើង។

# ឯកសារយោង


ABD, 2020, Cambodia's Economic Growth to Slow in 2020, Rebound Expected in 2021

https://www.adb.org/news/cambodias-economic-growth-slow-2020

ចូលអាន ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២

AMS, ២០២១, អាជ្ញាធរសម្រេចផ្អាកបណ្ដោះអាសន្នចំនួន 3 ទៀតក្នុងរាជធានីភ្នំពេញ

https://economy.ams.com.kh/authorities-decide-to-suspend-3-

ចូលអាន ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២

Data Commons, 2020, Cambodia

https://datacommons.org/place/country/KHM?utm_medium=explore&mprop=amount&
ថ្ងៃចូលអាន ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២

Fresh news, ២០២២, សម្ដេចតេជោ ហ៊ុន សែន អំពាវនាវឱ្យប្រជាពលរដ្ឋ ទៅចាក់ដូសទី៣ ដែលជាដូសជំរុញ ឱ្យបានគ្រប់ៗគ្នា (Sound inside)

http://freshnewsasia.com/index.php/en/localnews/247208-2022-06-27-10-19-46.html

ចូលអាន ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២

Khmer Times, 2020, Cambodia to lose $3bn in revenue from tourism sector,

https://www.khmertimeskh.com/50730893/cambodia-to-lose-3b

ចូលអាន ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២

MLVT, ២០១៩, ក្រុមជំនាញរបស់ ILO ចុះមកវាយតម្លៃលើសកម្មភាពប្រែក្លាយសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជាឱ្យទៅជាសេដ្ឋកិច្ចក្នុងប្រព័ន្ធ ២០១៤-២០១៨, ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
https://mlvt.gov.kh/index.php?option=com_k2&view=

ចូលអាន ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២

Rithipul, ២០២១, «សេដ្ឋកិច្ចក្រៅប្រព័ន្ធ» មានន័យដូចម្តេច?, ឫទ្ធីពល

https://www.rithipul.com/post/2020000223

ចូលអាន ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២

Trading Economics, 2022, Cambodia GDP

https://tradingeconomics.com/cambodia/gdp#:~:text=GDP%20in%20Cambodia% ថ្ងៃចូលអាន ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២

World bank, 2020, ការផ្តោតការសិក្សាពិសេសពីកម្ពុជាក្នុងកំឡុងពេលកូវីដ-១៩៖ គណនេយ្យភាពគ្រូបង្រៀន និងសិស្សនិស្សិត ទៅលើលទ្ធផលនៃការរៀនសូត្រ

https://pubdocs.worldbank.org/en/357291590674539831/pdf/CEU-Report-

ចូលអាន ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២

World Bank, 2022, ទស្សនៈទូទៅ

https://www.worldbank.org/km/country/cambodia/overview

ថ្ងៃចូលអាន ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២

WSDH, N/A, ជំងឺកូរ៉ូណាប្រភេទថ្មី COVID-19,

https://doh.wa.gov/sites/default/files/legacy/Documents/1600/coronavirus/

ចូលអាន ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០២២, ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២១

https://mef.gov.kh/macro-economic/%E1%9E%80%E1%9E%B

ថ្ងៃចូលអាន ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២

ខាន់ សុគុំមនោ, ២០២០, កម្ពុជាប្រកាសករណីទី១នៃវីរុសកូរ៉ូណាដែលរកឃើញលើជនជាតិចិនម្នាក់នៅខេត្តព្រះសីហនុ : https://khmer.voanews.com/a/first-case-of-coronavirus-

ចូលអាន ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២

ខ្មែរថាមស៍, ២០២១, អត្រាចាក់វ៉ាក់សាំងស្ទើរតែ ១០០% បានធ្វើឱ្យមានការសម្រេចចិត្តបើកថ្នាក់រៀនគ្រប់កម្រិត

https://www.khmertimeskh.com/50957041

ចូលអាន ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២

គង់ សុរិយា, ២០២២, អភិបាលរាជធានីភ្នំពេញបញ្ជាក់ពីការរៀបចំប្រារពពិធីបុណ្យចូលឆ្នាំប្រពៃណជាតិខ្មែរ, proverty area : https://www.propertyarea.asia/archives/96766

ចូលអាន ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២

គួច គន្ធារ៉ា, ២០២០, ទីភ្នាក់ងារថាមពលអន្តរជាតិព្យាករណ៍ពីកំណើនតម្រូវការអគ្គិសនីតិចតួចនៅឆ្នាំ ២០២១, RFI, https://www.rfi.fr/km/%E1%9E%A2%E1%9E%BA%E1%9E%9A%E1%

ចូលអាន ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២

ឆន ឌីណា, ២០២០, តើវិបត្តិកូវីដ១៩ បង្កផលប៉ះពាល់អ្វីខ្លះលើចង្វាក់ផ្គត់ផ្គង់សកល និងសកលភាវូបនីយកម្ម?, RFI : https://www.rfi.fr/km/%E1%9E%9F%E1%9F%

ចូលអាន ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២

ជា មុយគីម, ២០២០, កូវីដ ១៩៖ ផលប៉ះពាល់ដល់សង្គម និងសេដ្ឋកិច្ច, វ៉ុល ២ លេខ ៣, https://cd-center.org/wp-content/uploads/2020/04/P124_20200404_V2IS3_KH.pdf

ចូលអាន ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២

ជា វ៉ាន់យុទ្ធ (Chea Vanyuth), ២០២១, High electricity demand growth expected post-Covid, Khmer times : https://www.khmertimeskh.com/50885426/high-electricity

ចូលអាន ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២

ញឹម សុផល, ២០២០, ការឆ្លងជំបូង Covid-19 លើជនជាតិខ្មែរ, RFI,

https://www.rfi.fr/km/%E1%9E%80%E1%9E%98%E1%9F%92%E1%9E%

ថ្ងៃចូលអាន ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២

ថ្មីៗ, ២០១៧, ប្រទេសអាស៊ានទាំង១០ក្លាយជាសមាជិកអាស៊ានពេញសិទ្ធិថ្ងៃនៅណាខ្លះ?, https://thmeythmey.com/?page=detail&id=55278 ,

ថ្ងៃចូលអាន ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២

ទិត្យ គង់នៅ, ២០២១, វ៉ាក់សាំងដំបូងបានមកដល់កម្ពុជាដើម្បីជួយដល់ការប្រយុទ្ធនឹងជំងឺកូវីដ-១៩, Khmer Times : https://www.khmertimeskh.com/50811764/%E1%9E%

ថ្ងៃចូលអាន ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២

មួង ណារ៉េត, ២០២១, រដ្ឋាភិបាលប្រកាសបិទក្រុងភ្នំពេញនិងតាខ្មៅទាំងស្រុង១៤ថ្ងៃ, rfa,

https://www.rfa.org/khmer/news/health/hun-sen-the-situation

ចូលអាន ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២

ម៉ៅ ចាន់រិះ, ២០២១, កូវីដ-១៩ ផលប៉ះពាល់ធ្ងន់ធ្ងរលើវិស័យទេសចរណ៍, Khmer Times, https://www.khmertimeskh.com/50937220/%E1%9E%

ចូលអាន ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២

រាជបណ្ឌិតសភាកម្ពុជា, ២០២១, ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ លើសង្គម-សេដ្ឋកិច្ចកម្ពុជា p. 40

សែន ដារីត, ២០២០, Factory suspensions in Phnom Penh total 121, Khmer Times

https://www.khmertimeskh.com/50734544/factory-suspensions-in-phnom

ចូលអាន ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២

យឹម ស្រីលីន, ២០២២, ភ្ញៀវទេសចរជាង ៩០ ម៉ឺននាក់បានធ្វើដំណើរជុំវិញកម្ពុជាអំឡុងពិធីបុណ្យអុំទូក, ខ្មែរថាមស៍ : https://www.khmertimeskh.com/50975006/%E1%9E%

ចូលអាន ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២

ហំ ផានិត, ២០២០, សណ្ឋាគារនៅភ្នំពេញនិងនៅតាមខេត្តទេសចរណ៍មួយចំនួន បិទស្ទើរទាំងអស់, Cambonomist : https://cambonomist.com/news/most-hotels-forced-to-close

ចូលអាន ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២

អ៊ឹង ប៊ុនថន, ២០២១, កម្ពុជាប្រកាសពីការឆ្លងជាសហគមន៍ក្រោយរកឃើញកូវីដ១៩លើជនជាតិចិន៣២នាក់, https://www.rfi.fr/km/%E1%9E%80%E1%9E%98%E1%9F%92%E1%9E%96%

ថ្ងៃចូលអាន ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២

អេង គីមហុង, ២០២១, អ្នកសេដ្ឋកិច្ចៈផលប៉ះពាល់លើការផ្គត់ផ្គង់បន្លែនៅកម្ពុជាដែលបណ្តាលមកពីផ្អាកការចេញចូលព្រំដែនកម្ពុជា-វៀតណាមមានទំហំតិចតួច, RFI : https://www.rfi.fr/km/%E1%9E%80%E1%9E%98%E1%9F%92%E1

ចូលអាន ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២

អោ ស្រីពេជ្យ, ២០២១, កូវីដ១៩៖ តើការផ្អាកអាជីវកម្មម្ហូបអាហារ និងគ្រឿងស្រវឹងគ្រប់ប្រភេទ អាចប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាដែរឬ?, RFI ៖ https://www.rfi.fr/km/%E1%9E%80%E1%

ចូលអាន ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២

អោ ស្រីពេជ្រ, ២០២២, ឆ្នាំនេះភ្ញៀវទេសចរជិត៤លាន៦សែននាក់ដើរកម្សាន្តឱកាសចូលឆ្នាំខ្មែរដែលប្រហាក់ប្រហែលឆ្នាំ២០១៩,RFI, :https://www.rfi.fr/km/%E1%9E%80%E1%9E%

ចូលអាន ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២

ឌី ខេមបូឌា ដេលី, ២០២១, កម្ពុជាប្រកាសបើកប្រទេសឡើងវិញក្រោយពីជួបវិបត្តិជំងឺ Covid-19 ជិត ២ឆ្នាំ https://www.cambodiadaily.com/2021/11/02/10/44/57643/ :

ថ្ងៃចូលអាន ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ២០២១, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថល ២០២១-២០៣៥, ទំព័រ៦ : https://www.ocm.gov.kh/wp-ntent/uploads/2021/06/

ចូលអាន ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ២០២១, ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់សាំងបង្ការជំងឺកូវី-១៩ សំដៅបង្កើតឲ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ២០២១, https://www.pfm.gov.kh/document/publication/2021-05-

ចូលអាន ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២២

**ឧបសម្ព័ន្ធទី១.១**. លិខិតបញ្ជាក់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តតាកែវ

រដ្ឋបាលស្រុកសំរោង

លេខ: ០០៤/២២.ស.រ

**លិខិតបញ្ជាក់**

**អភិបាល នៃគណៈអភិបាលស្រុកសំរោង**

សូមធ្វើការបញ្ជាក់ថា៖ និស្សិតឈ្មោះ **ឆួយ ស៊ីថេត** ជានិស្សិតឆ្នាំទី៤ ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រាជធានីភ្នំពេញ ពិតជាបានចុះមកធ្វើការស្រាវជ្រាវ យកនូវឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទសម្រាប់ធ្វើសារណាបញ្ចប់ឆ្នាំសិក្សា នៅសាលាស្រុកសំរោង ខេត្តតាកែវ ចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ ដល់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ លើប្រធានបទ <<**ផលវិបាកសេដ្ឋកិច្ចក្នុងសម័យកូវីដ-១៩** (**សំរោង-តាកែវ**)>> ពិតប្រាកដមែន ។

លិខិតបញ្ជាក់នេះ ជូនឲ្យសាមីជនយកទៅប្រើប្រាស់ទៅតាមលទ្ធភាពដែលអាចប្រើប្រាស់បាន ។

ថ្ងៃចន្ទ ៨ រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

សំរោង , ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

**អភិបាលស្រុក**

**ប៊ុន គឹមហុង**

**ឧបសម្ព័ន្ធទី១.២៖** កម្រងសំណួរនៅពេលប្រមូលឯកសារនៅរដ្ឋបាលស្រុកសំរោង ខេត្តតាកែវ

**ផ្នែកទី១៖** សកម្មភាពសេដ្ឋកិច្ចទូទៅក្នុងស្រុងសំរោង មុខកើតមានវិបត្តិកូវិដ-១៩

១. តើស្រុកសំរោងមានឃុំ និងភូមិចំនួនប៉ុន្មាន?

................... ភូមិ

................... ឃុំ

២. តើមានប្រជាជនសរុបប៉ុន្មានក្នុងឆ្នាំ ២០១៩ និង ២០២១?

................ នាក់ នៅឆ្នាំ២០១៩

................. នាក់ នៅឆ្នាំ២០២១

៣. តើពួកគេប្រកបមុខរបរអ្វីខ្លះ? (ឆ្នាំ ..........)

កសិករ................ នាក់

កម្មកររោងចក្រ ................. នាក់

មិនពិតប្រាកដ ................ នាក់

៤. តើមីក្រូសហគ្រាស និង អាជីវករនិងកម្មករក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធប៉ុន្មាន?

................ សហគ្រាស

................អាជីវករនិងកម្មករក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៥. ចូរអ្នករៀបរាប់ពីសកម្មភាពសេដ្ឋកិច្ចផ្សេងៗមុនវិបត្តិនេះកើតឡើង។

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

**ផ្នែកទី២៖** ពត៌មានផ្សេងៗក្នុងសម័យកូវិដ-១៩

៦. តើមានអ្នកជម្ងឺសរុបប៉ុន្មាននាក់? ចំនួនអ្នកស្លាប់ដោយសារជម្ងឺកូវិដ-១៩?

ចំនួនអ្នកឆ្លង ................ នាក់

ចំនួនអ្នកស្លាប់ ................ នាក់

៧. មកដល់ពេលបច្ចុប្បន្ន តើអ្នកបានទទួលវ៉ាក់សាំងមានចំនួនប៉ុន្មាននាក់ និងប៉ុន្មានភាគរយ?

................ នាក់

................ ភាគរយ

៨. តើអាជីវកម្មប្រភេទណាខ្លះ ដែលត្រូវបានផ្អាកជាបណ្តោះអាសន្នក្នុងអំឡុងពេលផ្ទុះការឆ្លងរាលដាលខ្លាំង?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

៩. តើមានវិធានការអ្វីខ្លះក្នុងការបង្ការជម្ងឺឆ្លងមួយនេះ? (ឧទាហរណ៍ ការផ្អាតអាជីវកម្ម....)

.......................................................................................................................................

.............................................................................................................................................

.............................................................................................................................................

១០. តើមានការស្រង់ទិន្នន័យដែរឬទេ ចំពោះចំនួនមីក្រូសហគ្រាសដែលបានបិទទ្វារក្នុងសម័យកូវិដ-១៩?

................ ទីតាំង

១១. តើអ្នកបានជួយឧបត្ថមគាំទ្រដល់សហគ្រាសខ្នាតតូចទាំងនោះដែរឬទេ? បើមាន ចូលអ្នករៀបរាប់ខ្លះៗមក?

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

១២. តើរដ្ឋបាលស្រុក មានការសិក្សាស្រាវជ្រាវពីការប្រើប្រាស់ប្រព័ន្ធឌីជិថលរបស់ប្រជាជនដែរឬទេ? បើមាន តើមានប្រជាជនចំនួនប៉ុន្មានភាគរយអាចប្រើប្រាស់ប្រព័ន្ធឌីជិថលក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ?

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

តារាងទិន្នន័យអំពីអ្នកវិជ្ជមាន និងអ្នកស្លាប់ដោយសារកូវីដ១៩ នៅទូទាំងស្រុកសំរោង ខេត្តតាកែវ

| | |
|---|---|
| សរុប | ៧៧៧ នាក់ ស្រី ៤៣០ នាក់ |
| **សះស្បើយ** | ៧៤១ នាក់ ស្រី ៤០៧ នាក់ |
| បន្តព្យាបាល | ០០ នាក់ ស្រី ០០ នាក់ |
| ស្លាប់ | ៣៦ នាក់ ស្រី ២៣ នាក់ |

| **ឃុំដែលជាសះស្បើយ** | **សរុប** | **ស្រី** |
|---|---|---|
| រវៀង | ២០៤ | ៧៨ |
| សំរោង | ៥២ | ៣៦ |
| សិង្ហ | ៦៧ | ៤៥ |
| ជើងគួន | ២៩ | ១៨ |
| ជំរះពេន | ២៣ | ១៥ |
| ទ្រា | ៧៤ | ៤៨ |
| ស្លា | ៤៩ | ២៩ |
| បឹងជើង | ៣៩ | ២៤ |
| បឹងត្បូង | ៧០ | ៤៩ |
| ខ្វាវ | ២៧ | ១៧ |
| លំចង់ | ១០៧ | ៤៨ |
| សរុប | ៧៤១ | ៤០៧ |
| Total | ៧៧៧ | ៤៣០ |

| **ឃុំដែលបន្តព្យាបាល** | **សរុប** | **ស្រី** |
|---|---|---|
| រវៀង | ០ | ០ |
| សំរោង | ០ | ០ |
| សិង្ហ | ០ | ០ |
| ជើងគួន | ០ | ០ |
| ជំរះពេន | ០ | ០ |
| ទ្រា | ០ | ០ |
| ស្លា | ០ | ០ |
| បឹងជើង | ០ | ០ |
| បឹងត្បូង | ០ | ០ |
| ខ្វាវ | ០ | ០ |
| លំចង់ | ០ | ០ |
| សរុប | ០ | ០ |

| **ឃុំដែលមានអ្នកស្លាប់** | **សរុប** | **ស្រី** |
|---|---|---|
| | ៧ | ៤ |
| | ២ | ១ |
| | ១ | ១ |
| | ២ | ០ |
| | ៤ | ៣ |
| | ៤ | ៣ |
| | ៥ | ២ |
| | | |
| | ២ | ២ |
| | ៥ | ៤ |
| | ៤ | ៣ |
| សរុប | ៣៦ | ២៣ |

| **អ្នកវិជ្ជមានសរុបតាមឃុំ** | **សរុប** | **ស្រី** |
|---|---|---|
| | ២១១ | ៨២ |
| | ៥៤ | ៣៧ |
| | ៦៨ | ៤៦ |
| | ៣១ | ១៨ |
| | ២៧ | ១៨ |
| | ៧៨ | ៥១ |
| | ៥៤ | ៣១ |
| | ៣៩ | ២៤ |
| | ៧២ | ៥១ |
| | ៣២ | ២១ |
| | ១១១ | ៥១ |
| សរុប | ៧៧៧ | ៤៣០ |

តារាងទិន្នន័យអំពីចំនួនអ្នកចាក់វ៉ាក់សាំងនៅទូទាំងស្រុកសំរោង ខេត្តតាកែវ គិតត្រឹមថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តតាកែវ
រដ្ឋបាលស្រុកសំរោង

តារាងស្ថិតិប្រជាពលរដ្ឋ ប្រចាំថ្ងៃ បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ (ដូសទី១ ដូសទី២ ដូសទី៣ និង ដូសទី ៤)
ទូទាំងស្រុកសំរោង គិតត្រឹមម៉ោង ៥:០០ ល្ងាច ប្រចាំថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២

| ល.រ | អាយុ | សរុបរួម | ស្រី | បានចាក់ដូសទី១ | | បានចាក់ដូសទី២ | | បានចាក់ដូសទី៣ | | បានចាក់ដូសទី៤ | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| ១ | ៣ឆ្នាំ-៤ឆ្នាំ | 4,937 | 2,712 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| | សរុប | 4,937 | 2,712 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| ២ | ៥ ឆ្នាំ | 2,420 | 1,225 | 3 | 1 | 2 | 0 | 0 | 0 | 0 | 0 | |
| | សរុប | 2,420 | 1,225 | 3 | 1 | 2 | 0 | 0 | 0 | 0 | 0 | |
| ៣ | ៦ឆ្នាំ-១១ឆ្នាំ | 14,704 | 7,255 | 1 | 0 | 4 | 3 | 1 | 1 | 0 | 0 | |
| | សរុប | 14,704 | 7,255 | 1 | 0 | 4 | 3 | 1 | 1 | 0 | 0 | |
| ៤ | ១២ឆ្នាំ-១៧ឆ្នាំ | 13,823 | 6,650 | 4 | 3 | 1 | 1 | 4 | 4 | 65 | 36 | |
| | សរុប | 13,823 | 6,650 | 4 | 3 | 1 | 1 | 4 | 4 | 65 | 36 | |
| ៥ | ១៨ ឡើង | 93,330 | 50,521 | 13 | 8 | 4 | 2 | 37 | 26 | 303 | 160 | |
| | សរុប | 93,330 | 50,521 | 13 | 8 | 4 | 2 | 37 | 26 | 303 | 160 | |
| | សរុបរួម | 129,214 | 68,363 | 22 | 12 | 11 | 6 | 42 | 31 | 368 | 196 | |

កំណត់សំគាល់: +ចំពោះប្រជាពលរដ្ឋដែលមិនបានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដោយសារមូលហេតុ៖
+កិច្ចដំណើរការចាក់វ៉ាក់សាំង គឺកំពុងដំណើរការ

-ចំណាកស្រុក -មានផ្ទៃពោះ -មានជំងឺប្រចាំកាយ
-កើតជំងឺកូវីដ-១៩ -សម្រាលកូន ។

**ឧបសម្ព័ន្ធទី២.១.** កម្រងសំណួរសម្រាប់យកទៅសម្ភាសន៍អាជីវករទាំង ២១ រូប

## ការស្រាវជ្រាវស្តីអំពីផលប៉ះពាល់នៃជំងឺកូវីដ ១៩ លើអាជីវករក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងការងើបឡើងវិញ

**ថ្ងៃសម្ភាសន៍:** ______________________ **ទីកន្លែង (ភូមិ/ឃុំ):** ___________________________

**ឈ្មោះអ្នកត្រូវសម្ភាសន៍:**___________________

ប្រភេទជំនួញ: អ្នកលក់ខ្នាតតូច ឬតូបចល័ត/ មានហាង / ការិយាល័យ

ប្រភេទមុខរបររបស់និយោជិក: សណ្ឋាគារ/ផ្ទះសំណាក់, អ្នកលក់នៅក្នុងហាង/តូប

**សេចក្តីផ្តើម**

យើងកំពុងធ្វើការស្ទង់មតិតូចមួយអំពីផលប៉ះពាល់ដោយការរាលដាលនៃមេរោគកូវីដ១៩ មកលើមីក្រូសហគ្រាស និងអាជីវកម្មលក្ខណៈគ្រួសារ សម្រាប់យកទៅធ្វើ និងការពារសារណា និងស្ថានភាពសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ១៩ថមថយ ដើម្បីបញ្ចប់ឆ្នាំសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសាសេដ្ឋកិច្ច។ យើងនឹងសម្ភាសសហគ្រិនចំនួន ១៥ នាក់នៅក្នុងស្រុកសំរោង ខេត្តតាកែវ។ ការសម្ងាត់ របស់អ្នកនឹងត្រូវបានរក្សាទុកហើយគ្មាននរណាម្នាក់ដឹងពីអ្វីដែលអ្នកបាននិយាយទេ។ បទសម្ភាសន៍នេះអាចចំណាយពេល ១០ នាទី តើអ្នកយល់ព្រមឲ្យខ្ញុំធ្វើការសម្ភាសន៍អ្នកបានទេ?

**ចាស, យល់ព្រម (គូសវាស)** _____________

**ផ្នែកទី ១៖ ព័តិមានទូទៅស្តីពីអាជីវកម្ម**

1. តើសហគ្រាសរបស់អ្នកមានអាយុប៉ុន្មាន?

| គូស | អាយុ |
|---|---|
| | ក្រោម ២ |
| | 3 – ៥ |
| | ៦ – ៨ |
| | លើ ៩1 |

2. ប្រភេទអតិថិជន

| គូស | ប្រភេទអតិថិជន |
|---|---|
| | សិស្សសាលា |
| | អ្នកភូមិ |
| | ភ្ញៀវទេសចរណ៍ |
| | ភ្ញៀវទូទៅ |
| | អ្នកដំណើរ ឬអ្នកពីចំងាយ |
| | ផ្សេងៗ |

3. ចំនួនបុគ្គលិក

| គូស | ចំនួន |
|---|---|
| | តិចជាង ៣ |
| | ៤ – ៧ |
| | ៨ – ១០ |
| | ច្រើនជាង ១១ |

ផ្នែកទី ២៖ ស្ថានភាពមុខវិបត្តិកូវីដ–១៩

4. តើមុខពេលមានវិបត្តិកូវីដ-១៩ អាជីវកម្មរបស់អ្នកមានស្ថានភាពយ៉ាងដូចម្ដេច?

| គូស | **ស្ថានភាណមុខវិបត្តិកូវី-១៩** | **ហេតុផល** |
|---|---|---|
| | មិនល្អដូចតែក្នុងស្ថានភាពវិបត្តិនេះអ៊ីចឹង | |
| | ខ្ញុំមានអតិថិជនច្រើន សឹកតែផ្គត់ផ្គង់ទំនិញឬសេវាកម្មមិនទាន់ | |
| | ផលចំណេញមានភាពល្អគួរសមដែរ | |

| | | |
|---|---|---|
| | ផ្សេងៗ | |

5. តើអ្នកបានពង្រីកអាជីវកម្មរបស់អ្នកមុនវិបត្តិដែរឬទេ?

| គូស | ពង្រីកអាជីវកម្មមុនវិបត្តិ | ហេតុផល |
|---|---|---|
| | ទេ | |
| | បាទ/ចាស៎ | |
| | ផ្សេង | |

ផ្នែកទី ៣៖ ស្ថានភាពក្នុងវិបត្តិកូវីដ-១៩

6. តើសហគ្រាសរបស់ទទួលរងផលប៉ះពាល់ពីកូវីដ-១៩?

| គូស | ចម្លើយ |
|---|---|
| | ទេ |
| | បាទ/ចាស៎ |
| | ផ្សេង |

7. តើសហគ្រាសរបស់អ្នក ត្រូវបានបិទក្នុងកំឡុងពេលបិទខ្ទប់ដែរឬទេ?

| គូស | ចម្លើយ |
|---|---|
| | ទេ |
| | បាទ/ចាស៎ |
| | ផ្សេង |

8. តើអតិថិជនប្រភេទណា ដែលអ្នកបានបាត់បងក្នុងកំឡុងពេលមានវិបត្តិនេះ?

| គូស | ប្រភេទអតិថិជន |
| --- | --- |
| | សិស្សសាលា |
| | អ្នកភូមិ |
| | ភ្ញៀវទេសចរណ៍ |
| | ភ្ញៀវទូទៅ |
| | អ្នកដំណើរ ឬអ្នកពីចំងាយ |
| | ផ្សេងៗ |

9. តើមានចំណូលប៉ុន្មានភាគរយពីសហគ្រាសរបស់អ្នក ក្នុងវិបត្តិនេះ?

| គូស | ចំនួន |
| --- | --- |
| | ក្រោម ១០% |
| | ១០% ទៅ ៣០% |
| | ៣០% ទៅ ៥០% |
| | ៥០% ទៅ ៨០% |
| | ៨០% ទៅ ១០០% |
| | លើសពី ១០០% |

10. តើវាជះឥទ្ធិពលការគ្រប់ហិរញ្ញវត្ថុរបស់អ្នកដែរឬទេ?

បាទ/ចាស .....

ទេ .......

ក្នុងករណីបាទ/ចាស, បើរាប់ពីការជះឥទ្ធិពលពី១ ទៅ ១០ តើអ្នកស្ថិតនៅលេខទីប៉ុន្មានៈ

| គូស | ចំនួន |
| --- | --- |
| | ១ ទៅ ៣ |
| | ៤ ទៅ ៦ |
| | ៧ ទៅ ៨ |
| | ៩ ទៅ ១០ |

11. នៅពេលវិបត្តិវាចេះតែកើតឡើងម្តងហើយ ម្តងទៀត តើវាធ្វើឲ្យប៉ះពាល់ដល់ការរំពឹងទុករបស់អ្នកដែរឬទេ?

........................................................................................................................

……………………………………………………………………………………………………………………

12. តើផ្លូវចិត្តរបស់អ្នកបានទទួលរងនូវសម្ពាធដែរឬទេ?

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

**ផ្នែកទី ៤៖ ស្ថានភាពសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩**

ពេលនេះខ្ញុំចង់សួរពីស្ថានភាពផ្សេងៗ ក្រោយពេលវិបត្តិនេះត្រូវបានគ្រប់គ្រង។

13.បើនិយាយអំពីការរៀបចំខ្លួនសម្រាប់ការបង្ការជាមួយនឹងជម្ងឺឆ្លងផ្សេង តើអ្នកបានរៀន និងធ្វើអ្វីខ្លះ?

| គូស | ចម្លើយ | |
|---|---|---|
| | គោរពតាមការណែនាំរបស់ក្រសួងសុខាភិបាល | |
| | ដោយសារតែភាពភ័យក្លាច ខ្ញុំខិតខំស្វែងយល់ រៀនសូត្រពីបញ្ហាសុខភាពទូទៅតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ការផ្តល់ចំណេះដឹងផ្សេងៗ ដែលបច្ចុប្បន្ននេះការយល់ដឹងរបស់មានភាពប្រសើរជាងមុខ | |
| | ការការពារ និងប្រុងប្រយ័ត្នជានិច្ចជាមួយនឹងវីរុសកូវិដនេះ | |
| | ផ្សេងៗ | |

14. ស្ថាបភាពការផ្គត់ផ្គង់របស់អ្នក ចំពោះអតិថិជន ក្រោយវិបត្តិកូវីដ១៩ ថម

| គូស | ចម្លើយ | បញ្ជាក់ |
|---|---|---|
| | ការលក់ដូរមានភាពល្អប្រសើរឡើងវិញ | |
| | ពង្រីកមុខទំនិញ ដោយសារមានតម្រូវការច្រើន | |
| | ផ្គត់ផ្គង់មិនគ្រប់គ្រាន់ដល់អ្នកមានតម្រូវការ | |
| | មានតែអ្នកដើរច្រើន តែមិនសូវមានអ្នកទិញ | |
| | ការផ្គត់ផ្គង់នៅតែទាបដដែរ | |
| | ផ្សេងៗ | |

15. និយាយអំពីសេដ្ឋកិច្ចឌីជីថលវិញ តើបច្ចុប្បន្ននេះ អាជីវកម្មរបស់ប្រើប្រាស់ប្រព័ន្ធឌីជីថល (ប្រព័ន្ធផ្សព្វផ្សាយ, ការទូទាត់ប្រាក់, ឬប្រតិបត្តិការផ្សេងៗ ...)

| គូស | ចម្លើយ | បញ្ជាក់ |
|---|---|---|
| | ខ្ញុំបានប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការផ្សព្វផ្សាយលក់ទំនិញ និងសេវាកម្មរ | |
| | ទេ, ខ្ញុំមិនចេះប្រើប្រាស់វាទេ (មិនមានការយល់ដឹង) | |
| | រាល់ការទូទាត់តាមរយៈប្រព័ន្ធឌីជីថលនៅហាងរបស់ខ្ញុំ គឺកម្រមានណាស់ | |
| | រាល់ការទូទាត់របស់ហាងខ្ញុំ ភាគច្រើនតាមរយៈប្រព័ន្ធឌីជីថល | |
| | មានការទូទាត់ខ្លះៗដែរ | |
| | ផ្សេងៗ | |

16. និយាយអំពីចំណេះដឹងហិរញ្ញវត្ថុវិញ តើអ្នកមានការគ្រប់គ្រងវាដូចម្តេចខ្លះ?

| គូស | ចម្លើយ | បញ្ជាក់ |
|---|---|---|
| | មានការគ្រប់គ្រងបានល្អ ចំពោះការចំណាយ | |
| | ចេះបែងចែកលើប្រាក់ចំណូល | |
| | មានគោលការណ៍ច្បាស់លាស់ក្នុងការទិញទំនិញចូល | |
| | រៀបចំ និងសន្សំសំចៃ | |
| | គ្រប់គ្រងលើបំណុលផ្សេងៗ | |
| | ផ្សេងៗ | |

17. ជាចុងក្រោយ តើអ្នកមានសំណូមពរ ឬចង់និយាយអ្វីបន្ថែមទៀតដែរទេ?

.................................................................................................................................

.................................................................................................................................

.................................................................................................................................

**ឧបសម្ព័ន្ធទី២.២.** កម្រងរូបភាព

ឧបសម្ព័ន្ធទី២.២ ៖ កម្រងរូបភាពដែលបានមកថតមកពីរមណីយដ្ឋានភ្នំជីសូរ











អ្នកស្រី ផន ស៊ីណា | ០៦/មិថុនា/2022



លោក ឡាច សុខម | ០៦/មិថុនា/2022



លោកពូ ផា | ០៦/មិថុនា/2022



លោក ទឹម ហុងទ្រី | ២៩/មេសា/2022